# កិច្ចព្រមព្រៀង
# រវាង
# រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម
# ស្តីពី
# ការដឹកជញ្ជូនតាមផ្លូវទឹក

<<<<>>>

រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលតទៅហៅថា ភាគីកិច្ចព្រមព្រៀង

ដោយមានបំណងជំរុញមិត្តភាព រវាងប្រទេសទាំងពីរ ដើម្បីលើកកំពស់ការផ្តួចផ្តើមគំនិតជំរុញពាណិជ្ជកម្មអន្តរជាតិ និងកិច្ចសហការអន្តរជាតិ ដោយឈរលើមូលដ្ឋានសមភាព និងផលប្រយោជន៍រួម

ដោយមានបំណងសម្របសម្រួលការដឹកជញ្ជូនទំនិញ និងអ្នកដំណើរតាមផ្លូវទឹក រវាងប្រទេសទាំងពីរ ព្រមទាំងការដឹកជញ្ជូនទំនិញ និងអ្នកដំណើរឆ្លងកាត់ទៅមកប្រទេសទីបី នៅក្នុងទឹកដីនៃភាគីកិច្ចព្រមព្រៀង

ដោយយល់ឃើញថា មានការចាំបាច់ដើម្បីធ្វើឱ្យមានបច្ចុប្បន្នភាពលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក ដែលបានធ្វើឡើងនៅទីក្រុងហាណូយ នាថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដែលត្រូវជំនួសទាំងស្រុងដោយកិច្ចព្រមព្រៀងបច្ចុប្បន្ន

បានយល់ព្រមដូចខាងក្រោម ÷

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលបំណងនៃកិច្ចព្រមព្រៀង

គោលបំណងនៃកិច្ចព្រមព្រៀងបច្ចុប្បន្ន ÷

១. បង្កើតក្របខ័ណ្ឌច្បាប់ សម្រាប់ការអនុវត្តសេរីភាពនាវាចរណ៍ នៅតាមប្រព័ន្ធទន្លេមេគង្គ ប្រកបដោយប្រសិទ្ធភាព ដោយអនុវត្តតាមមាត្រា ៩ នៃកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍអាងទន្លេមេគង្គប្រកបដោយនិរន្តរភាព ដែលបានធ្វើឡើងនៅទីក្រុងឈាងរ៉ៃ នាថ្ងៃទី ៥ ខែ មេសា ឆ្នាំ ១៩៩៥ ។

២. បង្កើតលក្ខខណ្ឌអនុគ្រោះសម្រាប់នាវាចរណ៍ឆ្លងកាត់ និងនាវាចរណ៍ឆ្លងកាត់ព្រំដែននៅតាមផ្លូវទឹកនិយតកម្ម ។

### មាត្រា ២.- និយមន័យ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងបច្ចុប្បន្ន ÷

១. **ផ្លូវទឹកនិយតកម្ម** មានន័យថា ÷

ក. ផ្លូវទឹក និង គន្លងផ្លូវទឹកនៃប្រព័ន្ធទន្លេមេគង្គ ដែលស្ថិតនៅក្នុងទឹកដីនីមួយៗនៃភាគីកិច្ចព្រមព្រៀង ដែលមានបញ្ជីឈ្មោះនៅក្នុង **ឧបសម្ព័ន្ធ** A និង មានបង្ហាញនៅក្នុងផែនទីនៅក្នុង **ឧបសម្ព័ន្ធ** B ដែលឧបសម្ព័ន្ធទាំងនេះ ត្រូវចាត់ទុកជាផ្នែកសមាហរណ៍នៃកិច្ចព្រមព្រៀងបច្ចុប្បន្ន

ខ. ផ្លូវទឹកឯទៀតៗ ដែលភាគីកិច្ចព្រមព្រៀងទាំងពីរ កំណត់រួមគ្នា ។

២. **ផ្លូវឆ្លងកាត់** មានន័យថា ផ្នែកទាំងឡាយនៃផ្លូវទឹកនិយតកម្ម ដែលដាក់ឱ្យនាវាសមុទ្រ ធ្វើការដឹកជញ្ជូនឆ្លងកាត់ និង ដែលមានបញ្ជីឈ្មោះនៅក្នុង **ឧបសម្ព័ន្ធ** A និង មានបង្ហាញនៅក្នុងផែនទី នៅក្នុង **ឧបសម្ព័ន្ធ** B ហើយ ដែលរួមមាន ÷

ក. ផ្លូវទន្លេមេគង្គ/ទន្លេទៀន កាត់តាមមាត់ច្រកគឿទៀវ រហូតដល់កំពង់ផែភ្នំពេញ

ខ. ផ្លូវទន្លេបាសាក់/ទន្លេហូវ កាត់តាមមាត់ច្រកគឿឌិញអាន និងបន្តកាត់តាមវ៉ាមណាវផាស និងទន្លេមេគង្គ/ទន្លេទៀន រហូតដល់កំពង់ផែភ្នំពេញ ។

៣. **សេរីភាពនាវាចរណ៍** មានន័យថា សិទ្ធិដើម្បីប្រើប្រាស់ផ្លូវទឹកនិយតកម្មដោយសេរី សម្រាប់គោលបំណងនាវាចរណ៍ និង សកម្មភាពសេវាពាក់ព័ន្ធឯទៀតៗ ដោយគោរពតាមច្បាប់ វិធាន និង បទបញ្ជា ដែលបានកំណត់ដោយភាគីកិច្ចព្រមព្រៀង ស្របតាមកិច្ចព្រមព្រៀងបច្ចុប្បន្ន ។

៤. **អាជ្ញាធរមានសមត្ថកិច្ច** មានន័យថា ÷

ក. នៅក្នុងករណីរាជរដ្ឋាភិបាលកម្ពុជា - ក្រសួងសាធារណការ និងដឹកជញ្ជូន ឬ អាជ្ញាធរដទៃទៀត ដែលកំណត់ឡើងដោយក្រសួងនេះ

ខ. នៅក្នុងករណីរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម - ក្រសួងដឹកជញ្ជូន ឬ អាជ្ញាធរដទៃទៀត ដែលកំណត់ឡើងដោយក្រសួងនេះ ។

៥. **នាវាសមុទ្រ** មានន័យថា នាវា ឬ សំណង់បណ្តែតទឹកទាំងឡាយ ដែលពាក់ទង់ជាតិនៃភាគីកិច្ចព្រមព្រៀងណាមួយ ឬ រដ្ឋទី៣ និង បានចុះបញ្ជីជានាវាសមុទ្រ តាមច្បាប់នៃរដ្ឋម្ចាស់សញ្ជាតិ ព្រមទាំងនាវាឯទៀតៗ ដែលប្រកបអាជីវកម្មដឹកជញ្ជូនឆ្លងកាត់ ។

៦. **នាវាផ្លូវទឹកក្នុងប្រទេស** មានន័យថា នាវាទាំងឡាយ ឬ សំណង់បណ្តែតទឹកទាំងឡាយ ដែលរួមមានទាំងនាវាទូក ឬ សាឡង់ ក្រៅពីនាវាសមុទ្រ និងបានចុះបញ្ជីជានាវាផ្លូវទឹកក្នុងប្រទេស តាមច្បាប់នៃភាគីកិច្ចព្រមព្រៀង។

៧. **សំណង់បណ្តែតទឹក** មានន័យថា អង្គបណ្តែតទឹក - មិនត្រូវបានយកទៅប្រើប្រាស់ជាសំខាន់ ទុកជាមធ្យោបាយដឹកជញ្ជូននៅលើទឹកទេ ប៉ុន្តែត្រូវបានយកទៅប្រើប្រាស់សម្រាប់គោលបំណងពាណិជ្ជកម្មផ្សេងទៀត ដូចជាកន្លែងស្តុកទំនិញ ឬ កន្លែងចំណត កន្លែងខួងរ៉ែ កន្លែងសំណង់ ឬ កន្លែងជួសជុលនាវា ដងស្ទូច កញ្ចូមប្រេង ការជីកស្តារ ឬ ខ្សៀវ ដោយលើកលែងតែចំពោះអង្គបណ្តែតទឹកណា ដែលប្រើប្រាស់ជាផ្ទះ លំនៅដ្ឋាន ឬ កន្លែងពាណិជ្ជកម្ម ឬ ការិយាល័យ។

៨. **ទូកគ្រួសារ** មានន័យថា នាវាផ្លូវទឹកក្នុងប្រទេសតូចៗ ដែលមានចំណុះផ្ទុកមិនលើសពី១(មួយ)តោន ដឹកមនុស្សមិនលើសពី៥នាក់ និង មិនប្រើប្រាស់សម្រាប់គោលបំណងពាណិជ្ជកម្មឡើយ ។

៩. **ការដឹកជញ្ជូនឆ្លងកាត់** មានន័យថា ការដឹកជញ្ជូនទំនិញ ឬ អ្នកដំណើរតាមផ្លូវទឹកទៅមករវាងកំពង់ផែ ឬ ចំណតនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងកំពង់ផែ ឬ ចំណតនានានៃប្រទេសទីពី កាត់តាមផ្លូវឆ្លង កាត់ ។

១០. **ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន** មានន័យថា ការដឹកជញ្ជូនទំនិញ ឬ អ្នកដំណើរតាមផ្លូវទឹក រវាងកំពង់ផែ ឬ ចំណតនានា នៃព្រះរាជាណាចក្រកម្ពុជា និង កំពង់ផែ ឬ ចំណតនានានៃសាធារណរដ្ឋសង្គមនិយមវៀតណាម កាត់តាមផ្លូវទឹកនិយតកម្ម ដោយមិនរាប់បញ្ចូលការដឹកជញ្ជូនទំនិញ ឬ អ្នកដំណើរតាមផ្លូវទឹកទាំងឡាយណា ដែលដឹកនៅលើនាវា ដែលប្រកបអាជីវកម្មដឹកជញ្ជូនឆ្លងកាត់ឡើយ ។

១១. **ការបូតាស** មានន័យថា ការដឹកជញ្ជូនទំនិញ ឬ អ្នកដំណើរ រវាងកំពង់ផែ ឬ ចំណតចំនួនពីរ ស្ថិតនៅក្នុងទឹកដីរបស់ភាគីកិច្ចព្រមព្រៀងមួយ ។

១២. **ក្រុមកំពង់ផែ** មានន័យថា កំពង់ផែ និងចំណតទាំងអស់ ដែលស្ថិតនៅក្នុង នៅជិត ឬ នៅជុំវិញជាយក្រុង ទីក្រុង ឬ ខេត្ត-ក្រុង ឬ ផ្លូវទឹកនិយតកម្ម ដោយមិនពាក់ព័ន្ធនឹងកម្មសិទ្ធិ និងរចនាសម្ព័ន្ធគ្រប់គ្រងនៃកំពង់ផែ និងចំណតទាំងនោះឡើយ ។

១៣. **សមាជិកនាវិក** មានន័យថា បុគ្គលណាមួយ ដែលរាប់បញ្ចូលទាំងមេបញ្ជាការនាវា បរិបាលនាវា នាយ ឬ អ្នកបំរើការងារឯទៀតៗ ដែលបំពេញកិច្ចការនៅលើនាវាសមុទ្រ ឬ នាវាផ្លូវទឹកក្នុងប្រទេស ដែលទាក់ទងនឹងប្រតិបត្តិការនៃនាវានោះ ហើយជាអ្នកដែលមានឯកសារសម្គាល់ខ្លួនពាក់ព័ន្ធ ដែលចេញឱ្យដោយភាគីកិច្ចព្រមព្រៀងណាមួយ ឬ ប្រទេសទីពាជាម្ចាស់សញ្ជាតិ ព្រមទាំងមានឈ្មោះនៅក្នុងបញ្ជីនាវិករបស់នាវានោះ ។

១៤. **អ្នកដំណើរ** មានន័យថា បុគ្គលណាមួយ ដែលជិះនៅលើនាវា ដែលមិនមែនជាសមាជិកនាវិក និងមានឈ្មោះនៅក្នុងបញ្ជីអ្នកដំណើរ ។

១៥. **ទំនិញគ្រោះថ្នាក់** មានន័យថា ទំនិញ ដែលគេបានចាត់ថ្នាក់នៅក្នុងក្រម IMDG ឬ នៅក្នុងឯកសារបោះពុម្ពផ្សាយពាក់ព័ន្ធឯទៀតៗរបស់អង្គការសមុទ្រអន្តរជាតិ ថាជាទំនិញមានគ្រោះថ្នាក់ក្នុងការដឹកជញ្ជូនតាមសមុទ្រ និងសារធាតុ ឬ ទំនិញឯទៀតៗ ដែលជាសារធាតុអាចមានគ្រោះថ្នាក់ ប្រសិនបើគេបានដឹកសារធាតុ ឬ ទំនិញនោះតាមសមុទ្រ ហើយរួមមានធុងទទេរ សំណល់ប្រេងអណ្តែតនៅក្នុងធុង ឬ ឃ្លប់ទំនិញ ដែលគេបានប្រើប្រាស់សម្រាប់ដឹកទំនិញគ្រោះថ្នាក់ពីមុនមក វៀរលែងតែធុងទទេរ ធុង ឬ ឃ្លប់ទំនិញទាំងនោះ ត្រូវបានគេសំអាត សំងួត វិសុទ្ធកម្ម បាញ់សំអាតឧស្ម័នចេញ ឬ ធ្វើឱ្យខ្យល់ចេញចូលបានយ៉ាងសមស្រប ហើយបើនៅក្នុងករណីសមាសធាតុវិទ្យុសកម្ម គេត្រូវសំអាត និងបិទជិតត្រឹមត្រូវ ។ ទំនិញគ្រោះថ្នាក់ ដែលលើកឡើងនេះ មិនរាប់បញ្ចូលនូវទំនិញ ដែលបង្កើតបានជាផ្នែកនៃឧបករណ៍របស់នាវា ឬ នាវាភ័ណ្ឌ ដែលនាវានោះបានដឹកឡើយ ។

**មាត្រា ៣.~ វិសាលភាពនៃកិច្ចព្រមព្រៀង**

១. សម្រាប់គោលបំណងនៃការដឹកជញ្ជូនឆ្លងកាត់ និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន សេរីភាពនាវាចរណ៍ ត្រូវអនុវត្តនៅតាមផ្លូវទឹកនិយតកម្ម ដូចមានចែងនៅកថាខ័ណ្ឌទី១ មាត្រា២ ។

២. យោងតាមការកម្រិត ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងបច្ចុប្បន្ន សេរីភាពនាវាចរណ៍ ត្រូវបានផ្តល់ ÷

ក. ចំពោះនាវាទាំងឡាយរបស់ភាគីកិច្ចព្រមព្រៀង ក៏ដូចជានាវាទាំងឡាយរបស់រដ្ឋទី៣

ខ. សម្រាប់ការដឹកជញ្ជូនតាមផ្លូវសមុទ្រ ក៏ដូចជាការដឹកជញ្ជូនតាមផ្លូវទឹកក្នុងប្រទេស

គ. សម្រាប់ការដឹកជញ្ជូនឆ្លងកាត់ ក៏ដូចជាការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

ឃ. សម្រាប់ការដឹកជញ្ជូនទំនិញ ក៏ដូចជាអ្នកដំណើរ ។

៣. សេរីភាពនាវាចរណ៍ ត្រូវរាប់បញ្ចូលទាំងសិទ្ធិប្រើប្រាស់ផ្លូវទឹកទៅមកកំពង់ផែ ចំណត និងក្រុមកំពង់ផែ ដូចមានចែងនៅក្នុង **ឧបសម្ព័ន្ធ** C ដែលត្រូវចាត់ទុកជាផ្នែកសមាហរណ៍នៃកិច្ចព្រមព្រៀងបច្ចុប្បន្ន ។

៤. អគ្គាគាហកទាំងអស់នៃសេរីភាពនាវាចរណ៍ មានសិទ្ធិធ្វើបណ្តឹងដោយផ្ទាល់ និងផ្អែកលើបទប្បញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងបច្ចុប្បន្ន ។

៥. កិច្ចព្រមព្រៀងបច្ចុប្បន្ន មិនត្រូវអនុវត្តចំពោះ ÷

ក. នាវារបស់ភ្នាក់ងារអន្តរជាតិ នាវាបេសកកម្មការទូត នាវារបស់រដ្ឋ និងនាវាសង្គ្រោះដែលកាន់កាប់ ឬប្រើប្រាស់ដោយភាគីកិច្ចព្រមព្រៀងណាមួយ ដែលត្រូវគ្រប់គ្រងដោយលិខិតុបករណ៍ពាក់ព័ន្ធផ្សេងទៀត

ខ. ទូកគ្រួសាររបស់ប្រជាពលរដ្ឋ ដែលកំពុងរស់នៅតំបន់ព្រំដែន ដែលត្រូវគ្រប់គ្រងដោយលិខិតុបករណ៍ពាក់ព័ន្ធផ្សេងទៀត ដែលរួមមានទាំងបទបញ្ជាព្រំដែន ។

## ជំពូកទី ២

## សេរីភាពនាវាចរណ៍

### ជំពូករង ក

### ផ្លូវ ច្រកទ្វារព្រំដែន កំពង់ផែ និង ចំណត

**មាត្រា ៤.~ ផ្លូវសម្រាប់ការដឹកជញ្ជូនឆ្លងកាត់**

នាវាសមុទ្រ ដែលធ្វើការដឹកជញ្ជូនឆ្លងកាត់ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ផ្លូវឆ្លងកាត់ ។

**មាត្រា ៥.~ ផ្លូវសម្រាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន**

នាវាផ្លូវទឹកក្នុងប្រទេស ដែលធ្វើការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ផ្លូវទឹកនិយតកម្មណាមួយក៏បាន ។

## មាត្រា ៦.- ច្រកទ្វារព្រំដែន

១. នាវា ដែលអនុវត្តសេរីភាពនាវាចរណ៍ ក្នុងគោលបំណងនៃការដឹកជញ្ជូនឆ្លងកាត់ ឬ ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ត្រូវប្រើប្រាស់ច្រកទ្វារព្រំដែន នៅវិញស៊ឿង-ធឿងភឿក (វៀតណាម) - ក្អមសំណ (កម្ពុជា) ។

២. ក្រោយពីការស្នើសុំរបស់ភាគីកិច្ចព្រមព្រៀងណាមួយ ភាគីកិច្ចព្រមព្រៀង ត្រូវចូលចរចា ក្នុងគោលបំណង បើកច្រកទ្វារព្រំដែនបន្ថែមទៀត ដើម្បីជួយសម្រួលដល់ការដឹកជញ្ជូន ។

៣. កថាខ័ណ្ឌខាងលើ មិនត្រូវប៉ះពាល់ដល់សុពលភាពនៃកិច្ចព្រមព្រៀងមានស្រាប់ ស្តីពីការប្រើប្រាស់ច្រកទ្វារព្រំដែនឯទៀតៗ ដែលបានចូលជាធរមានរួចហើយ ដោយអាជ្ញាធរខេត្តទាំងឡាយនៃភាគីកិច្ចព្រមព្រៀងឡើយ ។

## មាត្រា ៧.- កំពង់ផែ ចំណត និង ក្រុមកំពង់ផែ

១. សេរីភាពនាវាចរណ៍ រួមមានសិទ្ធិប្រើប្រាស់កំពង់ផែ ចំណត និងក្រុមកំពង់ផែ ដូចមានចែងនៅក្នុង **ឧបសម្ព័ន្ធ** C ដែលត្រូវចាត់ទុកជាផ្នែកសមាហរណ៍នៃកិច្ចព្រមព្រៀងនេះ ។

២. អាជ្ញាធរមានសមត្ថកិច្ចនៃភាគីកិច្ចព្រមព្រៀងម្ខាង អាចប្រកាសអំពីការបើកឱ្យប្រើប្រាស់បន្ថែមទៀត នូវកំពង់ផែ ចំណត និង ក្រុមកំពង់ផែបាន ។ សេចក្តីប្រកាសនេះ ត្រូវជូនដំណឹងទៅភាគីកិច្ចព្រមព្រៀងម្ខាងទៀត តាមរយៈគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ ។

## មាត្រា ៨.- ផែនទីផ្លូវទឹក

១. ផ្លូវទឹកនិយតកម្ម ផ្លូវឆ្លងកាត់ និង ច្រកទ្វារព្រំដែន ដូចមានចែងនៅក្នុងមាត្រាខាងលើ មានបង្ហាញនៅក្នុងផែនទីផ្លូវទឹកនៅក្នុង **ឧបសម្ព័ន្ធ** B ដែលត្រូវចាត់ទុកជាផ្នែកសមាហរណ៍នៃកិច្ចព្រមព្រៀងបច្ចុប្បន្ន ។

២. បើកាលណា កាលៈទេសៈតម្រូវ លើកលែងតែនៅក្នុងករណីនៃការកែប្រែលក្ខខណ្ឌនាវាចរនៃលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ដូចជាការប៉ះទង្គិចជាដើម ភាគីកិច្ចព្រមព្រៀង ត្រូវធ្វើវិសោធនកម្ម កែប្រែ ឬ ជំនួសផែនទីផ្លូវទឹក ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី១បាន ។

# ជំពូកទី ២

# ការអនុវត្តសេរីភាពនាវាចរណ៍

## មាត្រា ៩.- ការមិនរើសអើង និង ឧនៃប្រទេសដែលទទួលការអនុគ្រោះ

១. ភាគីកិច្ចព្រមព្រៀង មានសិទ្ធិ និងកាលានុវត្តភាពស្មើគ្នា ក្នុងការអនុវត្តសេរីភាពនាវាចរណ៍ ។

២. ភាគីកិច្ចព្រមព្រៀងម្ខាង ត្រូវទប់ស្កាត់នូវវិធានការរើសអើងលើនាវានៃភាគីកិច្ចព្រមព្រៀងម្ខាងទៀត ។

៣. ភាគីកិច្ចព្រមព្រៀងម្ខាង ត្រូវផ្តល់ដល់នាវារបស់ភាគីកិច្ចព្រមព្រៀងម្ខាងទៀត នូវប្រព្រឹត្តកម្មតាមបែបប្រទេស ដែលទទួលការអនុគ្រោះ ពាក់ព័ន្ធនឹងបែបបទនៃការចូល និងការចេញដំណើររបស់នាវា បែបបទគយ

និង បែបបទផ្សេងៗទៀត ការប្រើប្រាស់ចំណតសម្រាប់ផ្ទុក និងផ្ទេរទំនិញ ការប្រើប្រាស់កន្លែងជួសជុលនាវា ចំណត ឃ្លាំងស្តុកទំនិញ និង ឋបនីយភណ្ឌផ្សេងទៀតៗ ក៏ដូចជាការផ្គត់ផ្គង់សម្ភារៈ ។

**មាត្រា ១០.~ កាបូតាស**

កាបូតាស ត្រូវបានរក្សាទុកចំពោះនាវារបស់ភាគីកិច្ចព្រមព្រៀងណាមួយ ដែលនៅក្នុងទឹកដីរបស់ភាគីនោះ មានផ្លូវទឹកនិយតកម្មពាក់ព័ន្ធស្ថិតនៅ វៀរលែងតែអាជ្ញាធរមានសមត្ថកិច្ចនៃភាគីកិច្ចព្រមព្រៀងនោះ អនុញ្ញាតជាក់ស្តែង ។

**មាត្រា ១១.~ ការចូលចតបន្តនៅកំពង់ផែ ឬ ចំណត**

ការលើកលែងកាបូតាស ដូចមានចែងនៅក្នុងមាត្រា១០ មិនរារាំងនាវាទាំងឡាយនៃភាគីកិច្ចព្រមព្រៀងណាមួយពី ÷

១. ការផ្ទុកទំនិញ ឬ ការផ្ទុកអ្នកដំណើរ ជាបន្តបន្ទាប់នៅកំពង់ផែ ឬ ចំណតជាច្រើន នៅក្នុងទឹកដីនៃភាគីកិច្ចព្រមព្រៀងម្ខាង សម្រាប់គោលបំណងដឹកទំនិញ ឬ អ្នកដំណើរទៅកាន់ទឹកដីនៃភាគីកិច្ចព្រមព្រៀងម្ខាងទៀត ។

២. ការផ្ទេរទំនិញ ឬ ផ្ទេរអ្នកដំណើរ ជាបន្តបន្ទាប់នៅកំពង់ផែ ឬ ចំណតជាច្រើន នៅក្នុងទឹកដីនៃភាគីកិច្ចព្រមព្រៀងម្ខាង ក្រោយពីបានទទួលដឹកទំនិញ ឬ អ្នកដំណើរទាំងអស់នេះ នៅក្នុងទឹកដីនៃភាគីកិច្ចព្រមព្រៀងម្ខាងទៀត ។

**មាត្រា ១២.~ ការអនុវត្ត និង ការធ្វើឱ្យស៊ីសង្វាក់គ្នានៃច្បាប់**

១. ច្បាប់ វិធាន និង បទបញ្ជាទាំងឡាយ ដែលនៅក្នុងនោះ សេរីភាពនាវាចរណ៍ ត្រូវបានអនុវត្ត ដែលរួមមាន បញ្ហាអន្តោប្រវេសន៍ គយ សុខាភិបាល បសុពេទ្យ និង ភូតគាមអនាម័យ និង ក្នុងគោលបំណងកែលំអលក្ខខណ្ឌនាវាចរណ៍ ត្រូវបានធ្វើឱ្យស៊ីសង្វាក់គ្នា តាមរយៈការធ្វើការសម្រេចចិត្តរួមគ្នា ។ សំណើនានា សម្រាប់ច្បាប់ វិធាន និង បទបញ្ជាទាំងឡាយ ដែលនឹងត្រូវដាក់ឱ្យស៊ីសង្វាក់គ្នានោះ ត្រូវធ្វើឡើងដោយគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ និងត្រូវធ្វើជូនភាគីកិច្ចព្រមព្រៀងសុំការអនុម័ត ។

២. ទំនាក់ទំនងជាកិច្ចសន្យារវាងប្រតិបត្តិករនាវា ម្ចាស់ទំនិញ អ្នកផ្តល់សេវា ក៏ដូចជាការទទួលខុសត្រូវផ្នែកសំណងរបស់គេ ចំពោះភាគីទី៣ ត្រូវមានចែងដោយឡែក តាមច្បាប់រដ្ឋប្បវេណី ច្បាប់ពាណិជ្ជកម្ម និងច្បាប់នាវាចរណ៍សមុទ្រ ដែលត្រូវស្របតាមស្តង់ដារ និង អនុសញ្ញាអន្តរជាតិ ដែលគេបានទទួលស្គាល់ជាទូទៅ ។

**មាត្រា ១៣.~ ការផ្តល់សេវាចាំបាច់**

ភាគីកិច្ចព្រមព្រៀង ត្រូវផ្តល់នូវសេវាចាំបាច់នានា នៅក្នុងទឹកដីរបស់ខ្លួន ដើម្បីបំពេញតាមតម្រូវការចាំបាច់របស់នាវា ប្រតិបត្តិករនាវា សមាជិកនាវិក អ្នកដំណើរ និង ពាណិជ្ជករ ។

**មាត្រា ១៤.~ ឯកសារសម្រាប់នាវាសមុទ្រ**

១. នាវាសមុទ្រ ត្រូវដាក់ជាប់ ហើយបើមានការស្នើសុំពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវបង្ហាញឯកសារទាំងឡាយ ដែលចេញឱ្យតាមអនុសញ្ញាអន្តរជាតិដែលកំពុងអនុវត្ត ឬ ច្បាប់ជាតិនៃរដ្ឋម្ចាស់សញ្ជាតិនាវា ។

២. នាវាសមុទ្រ ដែលអនុវត្តសេរីភាពនាវាចរណ៍ រួមមានទាំងនាវាសមុទ្រ ដែលបានប្រើប្រាស់សម្រាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែនផង មិនត្រូវទាមទារឱ្យមានលិខិតអនុញ្ញាតបែបណាមួយ ដែលចេញឱ្យដោយអាជ្ញាធរជាតិ ឬ អាជ្ញាធរមូលដ្ឋាននៃភាគីកិច្ចព្រមព្រៀងឡើយ ។

## មាត្រា ១៥.- ឯកសាររបស់នាវា និងលិខិតអនុញ្ញាតសម្រាប់នាវាផ្លូវទឹកក្នុងប្រទេស

១. នាវាផ្លូវទឹកក្នុងប្រទេស ដែលធ្វើការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ត្រូវមានជាក់ជាប់ ហើយបើមានការស្នើសុំពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវបង្ហាញនូវឯកសារ ដូចខាងក្រោម ÷

ក. វិញ្ញាបនប័ត្រចុះបញ្ជី

ខ. វិញ្ញាបនប័ត្រសុវត្ថិភាពបច្ចេកទេស និងការពារបរិស្ថាន ដែលចេញឱ្យដោយអាជ្ញាធរជាតិ ឬ សង្គមចំណាត់ថ្នាក់នាវា

គ. លិខិតអនុញ្ញាតដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដែលចេញឱ្យដោយអាជ្ញាធរមានសមត្ថកិច្ចសម្រាប់នាវានៃសញ្ជាតិនីមួយៗ

ឃ. បញ្ជីរាយមុខទំនិញ និង/ឬ បញ្ជីឈ្មោះអ្នកដំណើរ ជាមួយនឹងសេចក្តីពិស្តារអំពីលិខិតឆ្លងដែន

ង. វិញ្ញាបនប័ត្រធានារ៉ាប់រង ដែលធានាសំណងស៊ីវិលរបស់ម្ចាស់នាវាចំពោះភាគីទី៣ បើសិនជាច្បាប់តម្រូវ

ច. បញ្ជីឈ្មោះសមាជិកនាវិក ដែលបញ្ជាក់អំពីមុខងារ ក៏ដូចជាវិញ្ញាបនប័ត្រវិជ្ជាជីវៈ លិខិតឆ្លងដែន ហើយបើសិនជាចាំបាច់ វិញ្ញាបនប័ត្រចាក់ថ្នាំបង្ការរបស់សមាជិកនាវិកម្នាក់ៗ ។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវទទួលយក និងទទួលស្គាល់រាល់ឯកសារ ដែលចេញឱ្យស្របតាមច្បាប់ជាតិនៃភាគីកិច្ចព្រមព្រៀង ដោយរក្សាសិទ្ធិ ដើម្បីពិនិត្យលើភាពមិនប្រក្រតី បណ្តឹង និង បញ្ហាពាក់ព័ន្ធផ្សេងៗទៀតចំពោះភាគីកិច្ចព្រមព្រៀងម្ខាងទៀត ។

២. លិខិតអនុញ្ញាតដឹកជញ្ជូនឆ្លងកាត់ព្រំដែន ត្រូវចែកជាបីប្រភេទ ÷

ក. ប្រភេទទី១ : លិខិតអនុញ្ញាតសម្រាប់នាវា ដែលធ្វើដំណើរចេញចូលច្រើនលើក មានសុពលភាពអតិបរិមា ១២ (ដប់ពីរ) ខែ

ខ. ប្រភេទទី២ : លិខិតអនុញ្ញាតសម្រាប់នាវា ដែលធ្វើដំណើរចេញចូលមួយលើក មានសុពលភាពអតិបរិមា (ហុកសិប) ៦០ថ្ងៃ

គ. ប្រភេទពិសេស : លិខិតអនុញ្ញាតសម្រាប់នាវា ដែលដឹកទំនិញមានគ្រោះថ្នាក់ មានសុពលភាពអតិបរិមា (ហុកសិប) ៦០ថ្ងៃ ។

៣. ប្រសិនបើ នាវាមិនបានវិលត្រឡប់ទៅវិញនៅក្នុងរយៈពេលនៃលិខិតអនុញ្ញាត នោះអាជ្ញាធរមានសមត្ថកិច្ចនៃភាគីកិច្ចព្រមព្រៀងម្ខាងទៀត ត្រូវចេញលិខិតពន្យាពេលធ្វើដំណើរទោល ដែលទុករយៈពេលគ្រប់គ្រាន់សម្រាប់ការវិលត្រឡប់វិញ ដោយផ្អែកតាមលក្ខខណ្ឌដែលបញ្ជាក់អំពីមូលហេតុអាចទទួលយកបាន ។

៤. លិខិតអនុញ្ញាតដឹកជញ្ជូនឆ្លងកាត់ព្រំដែន ត្រូវកំណត់អំពីផ្លូវដាក់លាក់ ឬ កម្រិតការចូលកំពង់ផែ ចំណត ឬ ក្រុមកំពង់ផែពិតប្រាកដ ស្របតាមប្រភេទ សមត្ថភាព និងគោលបំណងរបស់នាវា ។

៥. លិខិតអនុញ្ញាតដឹកជញ្ជូនឆ្លងកាត់ព្រំដែន ត្រូវចេញឱ្យ ស្របតាមទម្រង់ ដូចមានចែងនៅក្នុង **ឧបសម្ព័ន្ធ D** ដែលចាត់ទុកជាផ្នែកសមាហរណ៍នៃកិច្ចព្រមព្រៀងបច្ចុប្បន្ន ។ ទម្រង់នៃលិខិតអនុញ្ញាតដឹកជញ្ជូនឆ្លងកាត់ព្រំដែន ត្រូវធ្វើឡើងជាភាសារបស់ភាគីចេញលិខិតអនុញ្ញាត និង ភាសាអង់គ្លេស ។

៦. ភាគីកិច្ចព្រមព្រៀងទាំងពីរ ត្រូវជូនពត៌មានគ្នាទៅវិញទៅមក អំពីបញ្ជីបច្ចុប្បន្នភាពនៃលិខិតអនុញ្ញាតដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដែលបញ្ជាក់អំពីលេខនាវា សមត្ថភាពដឹក ទំហំ និងលេខចុះបញ្ជី ព្រមទាំងអ្នកកាន់លិខិតអនុញ្ញាត ។

## មាត្រា ១៦.- ច្បាប់ និង បទបញ្ញត្តិពីអន្តោប្រវេសន៍ គយ សុខាភិបាល បសុពេទ្យ ភូតគាមអនាម័យ និងបរិស្ថាន

១. ច្បាប់ និងបទបញ្ញត្តិពីបញ្ហាអន្តោប្រវេសន៍ គយ សុខាភិបាល បសុពេទ្យ និងភូតគាមអនាម័យ និង បរិស្ថាន ត្រូវធ្វើឡើងដោយភាគីកិច្ចព្រមព្រៀង ។

២. ច្បាប់ និងបទបញ្ញា ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី១ ត្រូវស្របតាមអនុសញ្ញាអន្តរជាតិដែលកំពុងអនុវត្ត និងទំលាប់អនុវត្តជាលក្ខណៈអន្តរជាតិ ដែលគេទទួលស្គាល់ជាទូទៅ ។

៣. ការត្រួតពិនិត្យ ដែលបានធ្វើឡើងស្របតាមច្បាប់ និងបទបញ្ញា ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី១ មិនត្រូវបង្អាក់ការអនុវត្តសេរីភាពនាវាចរណ៍ដោយគ្មានការចាំបាច់ ឬ បង្កឱ្យមានការពន្យាពេលដោយគ្មានមូលហេតុនោះឡើយ ។

៤. សម្រាប់គោលបំណងនៃការអនុវត្តច្បាប់ និងបទបញ្ញាគយរបស់ភាគីកិច្ចព្រមព្រៀងនីមួយៗ ការធ្វើនាវាចរណ៍នៃនាវា ដែលធ្វើការដឹកជញ្ជូនឆ្លងកាត់ ត្រូវចាត់ទុកថាជាការធ្វើនាវាចរណ៍សមុទ្រ ។ ដោយលើកលែងចំពោះសព្វាវុធ គ្រាប់រំសេវ គ្រឿងផ្ទុះ ឬ សារធាតុវិទ្យុសកម្ម ថ្នាំញៀន សារធាតុធ្វើឱ្យវង្វេងស្មារតី សត្វដែលមានដោយកម្រ និងកំពុងទទួលរងគ្រោះថ្នាក់ទាំងអស់ នោះពុំតម្រូវឱ្យមានការអនុញ្ញាតណាមួយ សម្រាប់ការឆ្លងកាត់ ការនាំចូល ឬ ការនាំចេញនូវទំនិញឆ្លងកាត់ ពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសឆ្លងកាត់ឡើយ ។

## មាត្រា ១៧.- បែបបទនៃការដឹកជញ្ជូនឆ្លងកាត់ និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

១. នាវា ដែលធ្វើការដឹកជញ្ជូនឆ្លងកាត់ ត្រូវបំពេញបែបបទ ដែលទាក់ទងនឹងការត្រួតពិនិត្យផ្នែកអន្តោប្រវេសន៍ គយ សុខាភិបាល បសុពេទ្យ និង ភូតគាមអនាម័យ ដូចតទៅ ÷

ក. ពេលចូល ÷

(i). បែបបទច្រកចេញចូលតែមួយ ដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចវៀតណាម នៅវ៉ុងតាវ ឬ នៅមាត់ច្រកគឿឌិញអាន

(ii). បែបបទច្រកចេញចូលតែមួយ ដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា នៅភ្នំពេញ ឬ នៅកំពង់ផែ ឬ ចំណតគោលដៅឯទៀតៗ ។

ខ. ពេលចេញ :

(i). បែបបទច្រកចេញចូលតែមួយ ដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា នៅភ្នំពេញ ឬ នៅកំពង់ផែ ឬ ចំណតចេញដំណើរឯទៀតៗ

(ii). បែបបទច្រកចេញចូលតែមួយ ដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចវៀតណាម នៅច្រកទ្វារព្រំដែនវិញសឿង-ធឿងភឿក (វៀតណាម) - ក្អមសំណ (កម្ពុជា) ។

២. នាវា ដែលធ្វើការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ត្រូវបំពេញបែបបទទាំងអស់ ដែលទាក់ទងនឹងការត្រួតពិនិត្យផ្នែកអន្តោប្រវេសន៍ គយ សុខាភិបាល បសុពេទ្យ និងភូតគាមអនាម័យ នៅកំពង់ផែ ឬ ចំណតចេញដំណើរ និង នៅកំពង់ផែ ឬ ចំណតគោលដៅ ។ នៅក្នុងករណី ដែលពុំមានអាជ្ញាមានសមត្ថកិច្ចពាក់ព័ន្ធ សម្រាប់បំពេញបែបបទនៅកំពង់ផែ បែបបទទាំងនេះ ត្រូវធ្វើឡើងនៅច្រកទ្វារព្រំដែន ។

៣. នៅពេលមកដល់របស់នាវានៅមាត់ច្រកទន្លេ ឬ ច្រកទ្វារព្រំដែន ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី១ និង ទី២ មន្ត្រីទាំងអស់នៃអាជ្ញាធរមានសមត្ថកិច្ច ត្រូវឡើងលើ និងចាកចេញពីនាវា ជាមួយគ្នា ដើម្បីចៀសវាងការពន្យាពេលដែលគ្មានការចាំបាច់ ។

៤. ភាគីកិច្ចព្រមព្រៀង ត្រូវរៀបចំបែបបទ និង នីតិវិធីពាក់ព័ន្ធទាំងអស់ ដើម្បីបង្កលក្ខណៈឱ្យនាវា និង ភាគីមានផលប្រយោជន៍ទាំងអស់ បំពេញបែបបទទាំងនោះ នៅពេលថ្ងៃ និងពេលយប់ ។ តាមការជូនដំណឹងច្បាស់លាស់ពីនាវា អំពីពេលវេលាប៉ាន់ស្មានមកដល់ ឬ ពេលវេលាប៉ាន់ស្មានចេញដំណើររបស់នាវា ភាគីកិច្ចព្រមព្រៀង ត្រូវធានាថា មានអាជ្ញាធរមានសមត្ថកិច្ចជាបន្ទាន់ ដើម្បីចាត់ការធ្វើបែបបទ តាមនីតិវិធី នៅចំណុចធ្វើបែបបទ នៅពេលដែលនាវាមកដល់ ។

## មាត្រា ១៨.- កណ្តូធារកិច្ច

១. ភាគីកិច្ចព្រមព្រៀង ត្រូវផ្តល់សេវាកណ្តូធារកិច្ចគ្រប់គ្រាន់ដល់នាវាទាំងឡាយ ដែលស្នើសុំជំនួយកណ្តូធារកិច្ច ។

២. កណ្តូធារកិច្ចជាកាតព្វកិច្ច ត្រូវធ្វើឡើងតែចំពោះ ÷

ក. នាវា ដែលធ្វើការដឹកជញ្ជូនឆ្លងកាត់ ឬ ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន មានចំណុះសរុប ២៥០ GT ឡើងទៅ

ខ. នាវាឯទៀតៗ ដែលធ្វើការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដែលដឹកទំនិញគ្រោះថ្នាក់ ។

៣. ម្ចាស់ និងមេបញ្ជាការនៃនាវា ក្រៅពីនាវា ដែលមានចែងនៅក្នុងកថាខ័ណ្ឌទី២ មានសិទ្ធិទទួលកណ្តូធារកិច្ចក្នុងលក្ខខណ្ឌ ដែលការស្នើសុំរបស់គេ បានត្រូវធ្វើឡើងជាមុន និង ស្របតាមបទដ្ឋានអន្តរជាតិ ។

៤. បទបញ្ជាកណ្តូធារកិច្ច ត្រូវមានចែងជាអាទិ៍ ÷

ក. ការចេញវិញ្ញាបនប័ត្រលើកលែងកណ្តាការកិច្ច ឱ្យមេបញ្ជាការនាវាដែលមានបទពិសោធន៍ ឬ បរិបាលនាវា ដែលមានចំណេះដឹងមូលដ្ឋានល្អ ក៏ដូចជាលក្ខខណ្ឌទាំងឡាយ ដែលត្រូវបំពេញ ដើម្បីទទួលវិញ្ញាបនប័ត្រលើកលែងនោះ

ខ. ការចាត់ចែងកណ្តាការកិច្ច ដែលរួមមានទាំងទីតាំងនៃស្ថានីយ៍កណ្តាការកិច្ច និងនីតិវិធីនៃការឡើងលើនាវា និង ចុះពីនាវា

គ. ការលើកលែង ឬ ព្រំដែនសំណងទទួលខុសត្រូវ សម្រាប់សេវាកណ្តាការកិច្ច និងកណ្តាការ

ឃ. លក្ខណបច្ចេកទេស ដែលចាំបាច់សម្រាប់ការអនុវត្តគោលការណ៍ខាងលើ ដែលរួមមានទាំងនិយមន័យលំអិតនៃប្រភេទនាវា លក្ខណបច្ចេកទេសស្តីពីចំណុះតោន ការចាត់ថ្នាក់ទំនិញគ្រោះថ្នាក់ ក៏ដូចជាវិធាន ព្រមទាំងលក្ខខណ្ឌ និងវិធានបន្ថែមទៀត

ង. ផ្នែកឯទៀតៗនៃសេវាកណ្តាការកិច្ច ។

៥. បទបញ្ជាកណ្តាការកិច្ច ត្រូវកំណត់ឡើងដោយភាគីកិច្ចព្រមព្រៀង ។ គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ ត្រូវធ្វើសំណើសម្រាប់ការធ្វើឱ្យស៊ីសង្វាក់គ្នានៃបទបញ្ជាកណ្តាការកិច្ច ដែលត្រូវស្របនឹងបទដ្ឋាន និង ទំលាប់អន្តរជាតិ ដែលមានការទទួលស្គាល់ជាទូទៅ ។

## មាត្រា ១៩.~ សមាជិកនាវិក

១. សមាជិកនាវិករបស់នាវា នៃភាគីកិច្ចព្រមព្រៀងណាមួយ ត្រូវប្រើប្រាស់លិខិតឆ្លងដែន ឬ ឯកសារធ្វើដំណើរប្រហាក់ប្រហែល ស្របតាមច្បាប់ និងបទបញ្ជារបស់ប្រទេសចុះបញ្ជី ។ សមាជិកនាវិកនៃនាវា ដែលធ្វើការដឹកជញ្ជូនឆ្លងកាត់ ត្រូវប្រើប្រាស់លិខិតឆ្លងដែននាវិក ដែលមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ។

២. សមាជិកនាវិកនៃនាវារបស់ភាគីកិច្ចព្រមព្រៀងណាមួយ ឬ របស់រដ្ឋទី៣ ត្រូវបានអនុញ្ញាតឱ្យទាក់ទងជាមួយមន្ត្រីកុងស៊ុល ឬ តំណាងការទូតរបស់ខ្លួន សម្រាប់ដោះស្រាយបែបបទ ។

៣. សមាជិកនាវិកនៃនាវារបស់ភាគីកិច្ចព្រមព្រៀងម្ខាង ឬ របស់រដ្ឋទី៣ ត្រូវបានអនុញ្ញាតឱ្យឡើងគោក នៅក្នុងអំឡុងពេលស្នាក់នៅនៃនាវារបស់គេ នៅតាមកំពង់ផែ ឬ ចំណតរបស់ភាគីកិច្ចព្រមព្រៀងម្ខាងទៀត ស្របតាមច្បាប់ និងបទបញ្ជារបស់ភាគីកិច្ចព្រមព្រៀងម្ខាងទៀតនោះ ។

៤. នៅក្នុងករណីឈឺ សមាជិកនាវិកនៃនាវារបស់ភាគីកិច្ចព្រមព្រៀងម្ខាង ឬ របស់រដ្ឋទី៣ ត្រូវបានអនុញ្ញាតឱ្យស្ថិតនៅក្នុងទឹកដីនៃភាគីកិច្ចព្រមព្រៀងម្ខាងទៀត ក្នុងរយៈពេលដែលចាំបាច់ សម្រាប់ការព្យាបាលជំងឺស្របតាមច្បាប់ និងបទបញ្ជារបស់ភាគីកិច្ចព្រមព្រៀងម្ខាងទៀតនោះ ។

៥. សមាជិកនាវិកនៃនាវារបស់ភាគីកិច្ចព្រមព្រៀងម្ខាង ឬ របស់រដ្ឋទី៣ អាចចូលទៅក្នុងទឹកដីនៃកិច្ចព្រមព្រៀងម្ខាងទៀត សម្រាប់គោលបំណងរួមកំលាំងនៅលើនាវា ឬ មាតុភូមិនិវត្តន៍ ឬ សម្រាប់មូលហេតុឯទៀត ដែលទទួលយកដោយអាជ្ញាធរមានសមត្ថកិច្ច ក្រោយពីបានបំពេញនូវបែបបទរួចហើយ ដោយធានាថា បែបបទ

លក្ខខណ្ឌទាំងនេះ ត្រូវចែងអំពីបទដ្ឋានអប្បបរមា សម្រាប់ការថែរក្សា និងការកែលំអផ្លូវនាវាចរណ៍ ជាអាទិ៍ ទំហំ សមត្ថភាព និង/ឬ ជម្រៅស៊ីទឹករបស់នាវា ព្រមទាំងត្រូវកំណត់បញ្ជាក់អំពីលំហ រួមទាំងលំហខ្យល់នៅក្រោមស្ពាន ។

**មាត្រា ២៨.- ការហាមឃាត់ធ្វើឱ្យខូចលទ្ធភាពនាវាចរណ៍ និងភាគីកិច្ចយកចេញនូវភាពរាំងស្ទះ**

ភាគីកិច្ចព្រមព្រៀង ត្រូវទប់ស្កាត់រាល់ការអនុម័តដាក់ចេញនូវវិធានការ ឬ បទបញ្ជាណាមួយ ដែលអាចធ្វើឱ្យខូចដោយផ្ទាល់ ឬ ដោយប្រយោលដល់លទ្ធភាពនាវាចរណ៍ ឬ ដែលអាចធ្វើឱ្យលទ្ធភាពនាវាចរណ៍ ជួបការលំបាកខ្លាំងឡើងៗជាអចិន្ត្រៃយ៍ ហើយត្រូវចាត់វិធានការចាំបាច់នានាជាបន្ទាន់ ដើម្បីយកចេញនូវភាពរាំងស្ទះ និង ភាពគ្រោះថ្នាក់នានាដល់នាវាចរណ៍ ។

**មាត្រា ២៩.- ការកំណត់ផ្លូវផ្សេងទៀត**

នៅក្នុងករណីនៃការបិទផ្លូវ ឬ ឧបសគ្គនៅលើផ្លូវនាវាចរណ៍ នៅក្នុងទឹកដីនៃភាគីកិច្ចព្រមព្រៀងណាមួយ ភាគីនោះ ត្រូវបើកផ្លូវណាមួយផ្សេងទៀត ដែលសមស្របសម្រាប់ការដឹកជញ្ជូនជាបន្ទាន់ ដើម្បីធានាឱ្យមានការអនុវត្តសេរីភាពនាវាចរណ៍ដោយគ្មានការអាក់ខាន និង ត្រូវចាត់រាល់វិធានការ ដើម្បីស្តារឡើងវិញនូវលទ្ធភាពនាវាចរណ៍នៅលើផ្លូវធម្មតា ។ នៅក្នុងករណីដាក់ផ្លូវថ្មីឱ្យប្រើប្រាស់ជំនួសផ្លូវទឹកនិយតកម្ម ផ្លូវថ្មីទាំងនេះ ត្រូវមានយ៉ាងហោចណាស់ នូវបទបញ្ញត្តិចំពោះនាវាចរណ៍ ដូចគ្នានឹងផ្លូវទឹកនិយតកម្មចាស់ដែរ និងត្រូវចាត់ទុកថា ជាផ្លូវទឹកនិយតកម្ម នៅក្នុងអត្ថន័យនៃកិច្ចព្រមព្រៀងនេះ និងត្រូវស្ថិតនៅពេញលេញក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៣០.- កិច្ចសហប្រតិបត្តិការអំពីការថែរក្សា កែលំអ និងសញ្ញាជំនួយនាវាចរណ៍**

ភាគីកិច្ចព្រមព្រៀង ត្រូវធ្វើកិច្ចសហប្រតិបត្តិការជាអចិន្ត្រៃយ៍ ក្នុងគោលបំណងថែរក្សា និងកែលំអលទ្ធភាពនាវាចរណ៍នៃផ្លូវទឹកនិយតកម្ម និង ការវិនិយោគចាំបាច់នានា ដែលទាក់ទងនឹងផ្លូវទឹកនេះ ។ ដោយឡែក ភាគីកិច្ចព្រមព្រៀង ត្រូវ ÷

ក. ថែរក្សាផ្លូវទឹកនិយតកម្ម នៅក្នុងទឹកដីរបស់ខ្លួន ដើម្បីឆ្លើយតបនឹងលក្ខខណ្ឌបច្ចេកទេស ដូចមានចែងនៅក្នុងមាត្រា ២៧ ។

ខ. សហការគ្នា ក្នុងគោលបំណងកែលំអប្រឡាយ និងសញ្ញាជំនួយនាវាចរណ៍ ដោយផ្តល់អាទិភាពទៅលើផ្លូវឆ្លងកាត់ ។

គ. ស្វែងរកការគាំទ្រផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និង ការគាំទ្រឯទៀតៗ ពីគណៈកម្មការទន្លេមេគង្គ និង ពីអង្គការ និងប្រទេសនានា ។

## ជំពូកទី ៤

## គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ

### មាត្រា ៣១.- ការបង្កើតគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ

បង្កើតគណៈកម្មាធិការ ដែលមានសមាសភាព ជាតំណាងនៃភាគីកិច្ចព្រមព្រៀង និង មានឈ្មោះថា គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ ។

### មាត្រា ៣២.- ភារកិច្ចទូទៅរបស់គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ

គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ ត្រូវទទួលខុសត្រូវដូចខាងក្រោម ÷

ក. ធានាអនុវត្តកិច្ចព្រមព្រៀងបច្ចុប្បន្នឱ្យរលូន និង ផ្តល់ជាវិភាគទានយ៉ាងសកម្ម ដល់ការសម្រេចគោលបំណងនៃកិច្ចព្រមពៀងនេះ ។

ខ. កែលំ និង ធ្វើឱ្យស៊ីសង្វាក់គ្នានូវបទបញ្ជា និងលក្ខខណ្ឌឯទៀតៗ ដែលនៅក្នុងនោះ សេរីភាពនាវាចរណ៍ត្រូវបានអនុវត្ត ។

គ. ជំរុញ និង ពង្រឹងកិច្ចសហប្រតិបត្តិការរវាងភាគីកិច្ចព្រមព្រៀង នៅលើបញ្ហានានា ដែលទាក់ទងនឹងនាវាចរណ៍ នៅក្នុងប្រព័ន្ធទន្លេមេគង្គ និងសកម្មភាពពាក់ព័ន្ធនានា ។

ឃ. ទទួលអនុវត្តតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងបច្ចុប្បន្ន ។

### មាត្រា ៣៣.- ភារកិច្ចដោយឡែករបស់គណៈកម្មាធិការ

១. ក្នុងគោលបំណងនៃការធ្វើឱ្យស៊ីសង្វាក់គ្នាលើច្បាប់ វិធាន និង បទបញ្ជា និង ការសម្របសម្រួលនាវាចរណ៍នៅក្នុងប្រព័ន្ធទន្លេមេគង្គ គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ ត្រូវលើកសំណើនានា សម្រាប់ការអនុម័ត ហើយបើចាំបាច់ សម្រាប់ការកែប្រែ ដែលនឹងធ្វើឡើងដោយភាគីកិច្ចព្រមព្រៀង ÷

ក . វិធាន និងបទបញ្ជា សម្រាប់នាវាចរណ៍ប្រកបដោយសុវត្ថិភាព និង ការចៀសវាងនូវការប៉ះទង្គិច (រួមមាន ទាំងវិធានផ្លូវថ្នល់) ។

ខ. បទបញ្ជាកណ្តាលារកិច្ច ដូចមានចែងនៅក្នុងមាត្រា ១៨ ។

គ. តារាងតម្លៃថ្លៃឈ្នួល ដូចមានចែងនៅក្នុងមាត្រា ២៣ និង លក្ខខណ្ឌពាក់ព័ន្ធ ។

ឃ. វិធាន និងបទបញ្ជាស្តីពីសញ្ញាជំនួយនាវាចរណ៍ ។

ង. វិធាន និងបទបញ្ជាស្តីពីសេវាចរាចរណ៍នាវា ។

ច. វិធាន និងបទបញ្ជាស្តីពីការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ ។

ឆ. វិធាន និងបទបញ្ជាស្តីពីសេវារុករក និងសង្គ្រោះ និងការផ្តល់សមត្ថភាពសង្គ្រោះគ្រប់គ្រាន់ ។

ជ. ផែនការទប់ស្កាត់ការបំពុលឆ្លងកាត់ព្រំដែន និងទប់ទល់នឹងគ្រោះអាសន្ន ដែលត្រូវសម្របសម្រួល ។

ឈ. វិធាន និងបទបញ្ជាស្តីពីការស៊ើបអង្កេតគ្រោះថ្នាក់នាវា ។

ញ. បទបញ្ញាបច្ចេកទេសស្តីពីការពិនិត្យអង្កេតផ្លូវទឹក និងនាវា ។

ដ. វិធាន និងបទបញ្ញា ដែលចែងអំពីស្តង់ដារបណ្តុះបណ្តាលជាទូទៅ និង ស្តីពីការចេញវិញ្ញាបនប័ត្រ ។

ឋ. វិធាន និងបទបញ្ញាស្តីពីការប្រើប្រាស់ និងប្រតិបត្តិការនៃអង្គបណ្តែត ។

ឌ. វិធានឯទៀតៗ ដែលចាំបាច់ ។

២. បទបញ្ញាអនុវត្តន៍ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ ត្រូវអនុលោមទៅតាមកិច្ចព្រមព្រៀងបច្ចុប្បន្ន អនុសញ្ញាអន្តរជាតិ ក៏ដូចជាស្តង់ដារអន្តរជាតិ ដែលមានការទទួលស្គាល់ជាទូទៅ ។

៣. គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ ក៏ត្រូវទទួលខុសត្រូវផងដែរ ដូចខាងក្រោម ÷

ក. ផ្តល់អនុសាសន៍ចំពោះអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលបំណងប្រតិបត្តិតាមកិច្ចព្រមព្រៀងនេះ និង បទបញ្ញាអនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ ។

ខ. ស៊ើបអង្កេត និងលើកសំណើអំពីការបើកឱ្យប្រើប្រាស់ច្រកទ្វារព្រំដែនបន្ថែម ដូចមានចែងក្នុងមាត្រា ៦ ។

គ. ស៊ើបអង្កេត និងលើកសំណើអំពីការបើកឱ្យប្រើប្រាស់កំពង់ផែ ចំណត និងក្រុមកំពង់ផែ ដូចមានចែងនៅក្នុងមាត្រា ៧។

ឃ. ស៊ើបអង្កេត និងលើកសំណើអំពីការធ្វើវិសោធនកម្ម និងការកែប្រែផែនទីផ្លូវទឹក ដូចមានចែងនៅក្នុងមាត្រា ៨។

ង. បង្កើតនិងលើកសំណើអំពីលក្ខខណ្ឌប្រតិបត្តិការ និងបច្ចេកទេសអប្បបរមាដូចមានចែងនៅក្នុងមាត្រា២៧។

ច. ទទួលការទំនាក់ទំនងពីភាគីកិច្ចព្រមព្រៀង ពាក់ព័ន្ធនឹងផែនការ គម្រោង ឬ វិធានការថែរក្សា កែលំអ និង វិនិយោគ ដែលបានរៀបចំឡើង ឬ ធ្វើឡើងដោយភាគីកិច្ចព្រមព្រៀង ។

ឆ. ទទួលការស្នើសុំ សំណើ អនុសាសន៍ និងបណ្តឹងនានា ពីអាជ្ញាធរសាធារណៈ នីតិបុគ្គល ក្រុមហ៊ុន ឬ អង្គភាព ស្របច្បាប់ឯទៀតៗ គ្រប់សញ្ជាតិ ដែលរួមមានទាំងតំណាងនានានៃបរទេស ដែលប្រើប្រាស់ប្រព័ន្ធទន្លេមេគង្គ ហើយបើមានការស្នើសុំរបស់ភាគីកិច្ចព្រមព្រៀងណាមួយ ចូលរួមក្នុងសវនាការ ជាមួយអាជ្ញាធរ នីតិបុគ្គល ក្រុមហ៊ុន ឬ អង្គភាពស្របច្បាប់ទាំងនោះ និងដោះស្រាយនូវបញ្ហានានា តាមវិធីសមស្របបំផុត ។

ជ. សហការជាមួយគណៈកម្មការទន្លេមេគង្គ និង គណៈកម្មាធិការជាតិមេគង្គ ។

ឈ. លើកសំណើធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ បើចាំបាច់ ។

## មាត្រា ៣៤.~ ការរៀបចំស្ថាប័នរបស់គណៈកម្មាធិការ

១. គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ មានសមាសភាព ÷

ក. ក្រុមប្រឹក្សាប្រតិបត្តិ មានសមាសភាពរដ្ឋមន្ត្រី ១(មួយ)រូប ឬ តំណាងរបស់រដ្ឋមន្ត្រី ១(មួយ)រូប នៃភាគីកិច្ចព្រមព្រៀងនីមួយៗ ដែលជាអ្នកទទួលខុសត្រូវក្នុងនាវាចរណ៍ ។

ខ. គណៈកម្មការ មានសមាសភាពសមាជិក ៣(បី)រូប ដែលតែងតាំងដោយអាជ្ញាធរមានសមត្ថកិច្ចនៃភាគីកិច្ចព្រមព្រៀងនីមួយៗ ដែលនៅក្នុងសមាសភាពនោះ យ៉ាងហោចណាស់ មានថ្នាក់អគ្គនាយក ១(មួយ)រូប ។

គ. ក្រុមការងារ មានសមាសភាពតំណាងនានា ដែលតែងតាំងដោយអាជ្ញាធរមានសមត្ថកិច្ច ដែលជាអ្នកមានបទពិសោធន៍ អំពីបញ្ហានានាស្របទៅតាមក្រុមការងារពាក់ព័ន្ធ ។

ឃ. ក្រុមពិគ្រោះយោបល់ដឹកជញ្ជូនតាមផ្លូវទឹក មានតំណាងនានា ដែលតែងតាំងឡើងដោយសមាគមនដឹកជញ្ជូនតាមផ្លូវទឹកពាក់ព័ន្ធ ។

២. យោងតាមការសម្រេចយល់ព្រមជាមុន ឬ ការសម្រេចយល់ព្រមជាបន្ទាប់ ដោយរដ្ឋាភិបាលនីមួយៗ ដែលត្រូវបានស្នើសុំតាមពេលវេលាកំណត់ ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវមានអំណាចដើម្បី ÷

ក. រៀបចំ និងអនុម័តបទបញ្ជាអនុវត្តន៍ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងបច្ចុប្បន្ន ។

ខ. ធ្វើការសម្រេចតាមផ្លូវច្បាប់ណាមួយ ជាប្រភេទបញ្ញត្តិទូទៅ ឬ និយតកម្ម ដែលទាក់ទងនឹងការអនុវត្តកិច្ចព្រមព្រៀងបច្ចុប្បន្ន ។

៣. គណៈកម្មការ ត្រូវទទួលខុសត្រូវដូចខាងក្រោម ÷

ក. រៀបចំការសម្រេចនានា ដែលនឹងត្រូវសម្រេចដោយក្រុមប្រឹក្សាប្រតិបត្តិ ។

ខ. ចេញអនុសាសន៍ ដូចមានចែងនៅក្នុងចំណុច **ក** កថាខណ្ឌទី៣ មាត្រា ៣៣ ។

គ. ដោះស្រាយជាមួយភាគីទី៣ ដូចមានចែងនៅក្នុងចំណុច **ឆ** និង **ជ** កថាខណ្ឌទី**៣** មាត្រា ៣៣ ។

ឃ. ចេញគោលការណ៍ណែនាំ និងអនុសាសន៍ ស្តីពីទំលាប់អនុវត្តល្អអំពីផ្នែកទាំងអស់នៃនាវាចរណ៍នៅក្នុងប្រព័ន្ធទន្លេមេគង្គ ។

ង. ធ្វើការសម្រេចនានា នៅក្នុងករណីនីមួយៗ ដែលទាក់ទងនឹងការអនុវត្តកិច្ចព្រមព្រៀងបច្ចុប្បន្ន ។

ច. ចាត់វាល់វិធានការដែលចាំបាច់ ដើម្បីធានាឱ្យមានការអនុវត្តសេរីភាពនាវាចរណ៍ និងទប់ទល់នឹងភាពរាំងស្ទះដល់នាវាចរណ៍ ។

៤. ក្រុមការងារ ត្រូវទទួលខុសត្រូវរៀបចំ និងសម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាប្រតិបត្តិ និងគណៈកម្មការព្រមទាំងកិច្ចការឯទៀតៗ ដែលក្រុមប្រឹក្សាប្រតិបត្តិ ឬ គណៈកម្មការ ប្រគល់ឱ្យ ។

៥. ក្រោយការស្នើសុំ ឬ ដោយគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ក្រុមពិគ្រោះយោបល់ដឹកជញ្ជូនតាមផ្លូវទឹក ត្រូវលើកអនុសាសន៍ ទៅអង្គភាពនានានៃគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ ។

៦. នៅកិច្ចប្រជុំលើកទី១របស់ខ្លួន ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវអនុម័តបទបញ្ជា ដែលចែងអំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ ។

## ជំពូកទី ៥

## ដំណោះស្រាយវិវាទ

### មាត្រា ៣៥.- ការចរចា

ភាពខ្វែងគ្នាណាមួយ ដែលអាចកើតមានឡើងនៅក្នុងការបកស្រាយ ឬ ការអនុវត្តកិច្ចព្រមព្រៀងបច្ចុប្បន្ន ត្រូវដោះស្រាយគ្នាតាមការចរចា និងការពិគ្រោះយោបល់ នៅក្នុងគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គ ។ ប្រសិន បើភាពខ្វែងគ្នា នៅតែមិនអាចដោះស្រាយបាន ត្រូវលើកយកបញ្ហានោះទៅដោះស្រាយនៅថ្នាក់រដ្ឋាភិបាលនៃភាគីកិច្ច ព្រមព្រៀង ។

### មាត្រា ៣៦.- មជ្ឈត្តការ

វិវាទ ទាក់ទងនឹងកិច្ចព្រមព្រៀងនេះ ដែលមិនអាចដោះស្រាយបានតាមមាត្រា ៣៥ ឬ វិវាទទាក់ទងនឹងអនុសញ្ញាដែលកំពុងអនុវត្តឯទៀតៗ រវាងភាគីកិច្ចព្រមព្រៀង ដែលទាក់ទងនឹងបញ្ហាដែលជាកម្មវត្ថុនៅក្នុងកិច្ចព្រមព្រៀងបច្ចុប្បន្ន ត្រូវដាក់បញ្ជូនទៅមជ្ឈត្តការ ស្របតាមគោលការណ៍នៃច្បាប់អន្តរជាតិ ។

## ជំពូកទី ៦

## អវសានបញ្ញត្តិ

### មាត្រា ៣៧.- ការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមាន នៅកាលបរិច្ឆេទនៃការជូនដំណឹងចុងក្រោយ ដែលចេញដោយភាគីកិច្ចព្រមព្រៀង ដែលថា នីតិវិធីច្បាប់ ដែលតម្រូវឱ្យមានតាមច្បាប់ជាតិរបស់គេ ត្រូវបានបំពេញចប់សព្វគ្រប់ ។

២. នៅពេលចុះហត្ថលេខាភ្លាម កិច្ចព្រមព្រៀងនេះ ត្រូវដាក់ឱ្យអនុវត្តជាបណ្ដោះអាសន្ន រហូតដល់ចប់នីតិវិធីដូចមានចែងនៅក្នុងកថាខ័ណ្ឌទី១ ។

### មាត្រា ៣៨.- រយៈពេល

កិច្ចព្រមព្រៀងបច្ចុប្បន្ន ត្រូវមានសុពលភាព នៅក្នុងរយៈពេល ៥(ប្រាំ)ឆ្នាំ និងត្រូវមានសុពលភាពឡើងវិញដោយឯកឯងសម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំបន្ទាប់ទៀត វៀរលែងតែត្រូវបានបញ្ចប់ដោយភាគីកិច្ចព្រមព្រៀងណាមួយតាមរយៈលិខិតការទូត នៅក្នុងរយៈពេល ៦(ប្រាំមួយ)ខែ នៅមុនពេលផុតកំណត់នៃរយៈពេល ៥(ប្រាំ)ឆ្នាំបច្ចុប្បន្ន ។

### មាត្រា ៣៩.- ការកែប្រែ ការធ្វើវិសោធនកម្ម និង ការកែលំអ

១. ប្រសិនបើភាគីកិច្ចព្រមព្រៀងម្ខាង ជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅភាគីកិច្ចព្រមព្រៀងម្ខាងទៀត អំពីបំណងរបស់ខ្លួន ដើម្បីចាប់ផ្ដើមការចរចា ដើម្បីកែប្រែ ធ្វើវិសោធនកម្ម ឬ កែលំអកិច្ចព្រមព្រៀងនេះ ការចរចានេះ ត្រូវចាប់ផ្ដើមធ្វើឡើងនៅក្នុងរយៈពេល ៦(ប្រាំមួយ)ខែ ក្រោយកាលបរិច្ឆេទនៃការទទួលការជូនដំណឹងនោះ ។

២. សេចក្ដីសម្រេចខាងក្រោមនេះ ត្រូវធ្វើឡើងនៅក្នុងលិខិតុបករណ៍របស់រដ្ឋមន្ត្រីមានសមត្ថកិច្ចនៃភាគីកិច្ចព្រមព្រៀង ដែលនឹងត្រូវចូលជាធរមានភ្លាម ÷

ក. សេចក្ដីសម្រេច ដើម្បីដាក់បន្ថែមផ្លូវទឹកទៅក្នុងបញ្ជីផ្លូវទឹកនិយតកម្ម ដូចមានចែងនៅក្នុងចំណុច ខ កថាខ័ណ្ឌទី១ មាត្រា ២ ។

ខ. សេចក្ដីសម្រេច ដើម្បីប្រកាសអំពីការបើកប្រើប្រាស់ច្រកទ្វារព្រំដែនបន្ថែម ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី២ មាត្រា ៦ ។

គ. សេចក្ដីសម្រេច ដើម្បីធ្វើវិសោធនកម្ម កែប្រែ ឬ ជំនួសផែនទី ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី២ មាត្រា ៨ ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ជា២(ពីរ)ច្បាប់ ជាភាសាវៀតណាម ភាសាខ្មែរ និងភាសាអង់គ្លេស ដែលអត្ថបទទាំងអស់ មានតម្លៃគតិយុត្តិស្មើគ្នា ។ ក្នុងករណីមានការខ្វែងគ្នានៅក្នុងការបកស្រាយ នោះភាសាអង់គ្លេស ត្រូវចាត់ទុកជាបានការ ។

**ក្នុងនាមរដ្ឋាភិបាល**
**នៃសាធារណរដ្ឋសង្គមនិយមវៀតណាម**

**ឡេ ម៉ាញ់ហ៊ុង**
អនុរដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

**ក្នុងនាមរាជរដ្ឋាភិបាល**
**កម្ពុជា**

**មុំម ស៊ីប៊ុន**
រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន

## ឧបសម្ព័ន្ធ A

## បញ្ជីផ្លូវទឹកនិយតកម្ម និង ផ្លូវឆ្លងកាត់

### ១. ផ្លូវទឹកនិយតកម្មនៅប្រទេសកម្ពុជា

| លេខកំណត់ផ្លូវ មានបង្ហាញនៅក្នុងផែនទីផ្លូវទឹកក្នុងឧបសម្ព័ន្ធ B | ឈ្មោះផ្លូវទឹក | ចំណុចដើម-ចំណុចចប់ | ប្រវែង (គ.ម) |
|---|---|---|---|
| 1 a | បឹងទន្លេសាប | ចុងឃ្នៀស-កំពង់ឆ្នាំង | ១៥២ |
| 1 b | ទន្លេសាប | កំពង់ឆ្នាំង-ភ្នំពេញ | ១០០ |
| 1 c | ទន្លេមេគង្គ | ភ្នំពេញ-ច្រកទ្វារព្រំដែនក្អមសំណ | ១០២ |
| 2 | ទន្លេមេគង្គ | កំពង់ចាម-ភ្នំពេញ | ១០៦ |

### ២. ផ្លូវទឹកនិយតកម្មនៅប្រទេសវៀតណាម

| លេខកំណត់ផ្លូវ មានបង្ហាញនៅក្នុងផែនទីផ្លូវទឹកក្នុងឧបសម្ព័ន្ធ B | ឈ្មោះផ្លូវទឹក | ចំណុចដើម-ចំណុចចប់ | ប្រវែង (គ.ម) |
|---|---|---|---|
| 1 a | ទន្លេមេគង្គ/ទៀន | ច្រកទ្វារព្រំដែនវិញស៊ឿង/ក្អមសំណ-ចំណុចប្រសព្វព្រែកជីកតានចាវ | ១២.៣ |
| 1 b | ទន្លេមេគង្គ/ទៀន | ចំណុចប្រសព្វព្រែកជីកតានចាវ-ចំណុចប្រសព្វព្រែកជីកកេងថាប់ម៉យលេខ២ | ៥៦.៣ |
| 1 c | ទន្លេមេគង្គ/ទៀន | ចំណុចប្រសព្វព្រែកជីកតានចាវ-ចំណុចប្រសព្វទន្លេវ៉ាមណាវ | ២៣.៥ |
| 1 d | ទន្លេមេគង្គ/ទៀន | ចំណុចប្រសព្វព្រែកជីកគេញថាប់ម៉យលេខ១-ចំណុចប្រសព្វព្រែកជីករ៉ាច់គីហុន | ១១២.៩ |
| 1 e | ទន្លេមេគង្គ/ទៀន | ចំណុចប្រសព្វព្រែកជីករ៉ាច់គីហុន-សមុទ្រ | ៤១.១ |

| | | | |
|---|---|---|---|
| 2a.1 | ទន្លេវ៉ាមណាវ | ចំណុចប្រសព្វទន្លេមេគង្គ/ទៀន-ចំណុចប្រសព្វទន្លេបាសាក់/ហូវ | ៦.៥ |
| 2a.2 | ទន្លេបាសាក់/ហូវ | ចំណុចប្រសព្វវ៉ាមណាវ-កំពង់ផែកាន់ថឺ | ៦៨ |
| 2a.3 | ទន្លេបាសាក់/ហូវ | កំពង់ផែកាន់ថឺ-សមុទ្រ (ពោង0) | ១១៧.៨ |
| 2b.1 | ព្រែកជីកតានចូវ | ចំណុចប្រសព្វទន្លេមេគង្គ/ទៀន-ចំណុចប្រសព្វទន្លេបាសាក់/ហូវ | ៩.៥ |
| 2b.2 | ទន្លេបាសាក់/ហូវ | ចំណុចប្រសព្វព្រែកជីកតានចូវ-ចំណុចប្រសព្វព្រែកវ៉ាមណាវ | ៣៩.៥ |
| 3a.1 | គេញថាប់ម៉ឺយលេខ១ | ចំណុចប្រសព្វទន្លេមេគង្គ/ទៀន-ទន្លេវ៉ាមកូតី | ៩០.៥ |
| 3a.2 | ទន្លេវ៉ាមកូតី | គ.មលេខ៤៣-គ.ម៨២ | ៣៩ |
| 3a.3 | គេញធូធូ | ចំណុចប្រសព្វទន្លេវ៉ាមកូតី-ចំណុចប្រសព្វវ៉ាមកូដុង | ១០.៥ |
| 3a.4 | ទន្លេវ៉ាមកូដុង | គ.ម១០៥-គ.ម១០៨ | ៣ |
| 3a.5 | ទន្លេបេនលុក-ចឺដេម | ចំណុចប្រសព្វវ៉ាមកូដុង-ចំណុចប្រសព្វគេញដូយ | ២០ |
| 3a.6 | គេញដូយ | ចំណុចប្រសព្វទន្លេចឺដេម-ចំណុចប្រសព្វវ៉ាច់អុងឡឺន | ៨.៥ |
| 3a.7 | គេញតេ | ចំណុចប្រសព្វអុនឡឺន-ទីក្រុងហូជីមិញ | ៤.៥ |
| 3b.1 | គេញចឺហ្គាវ | វ៉ាច់គីហឺន-វ៉ាច់ឡា | ២៨ |
| 3b.2 | ទន្លេវ៉ាមណាវ | គ.ម៨-គ.ម១៨ | ១០ |
| 3b.3 | គេញនឿកម៉ាន | ចំណុចប្រសព្វទន្លេវ៉ាមកូ-ចំណុចប្រសព្វទន្លេកានយឹក | ២ |
| 3b.4 | ទន្លេកានយឹក | ចំណុចប្រសព្វគេញណុកម៉ាន-គ.ម 0 | ២២ |
| 3b.5 | គេញកាយខ | គ.ម ៣+៥00ម-គ.ម0 | ៣.៥ |
| 3b.6 | វ៉ាច់អុងឡឺន | គេញកាយខ-ចំណុចប្រសព្វគេញតេ | ៥ |

| | | | |
|---|---|---|---|
| 3b.7 | គេញគេ | ចំណុចប្រសព្វរ៉ាច់អុងឡឺន-ទីក្រុងហូជីមិញ | ៤.៥ |
| 3c.1 | ទន្លេវ៉ាមកូ | រ៉ាច់ឡា-ចំណុចប្រសព្វទន្លេសយវ៉ាប់ | ២៤ |
| 3c.2 | ទន្លេស្វាយរ៉ាប់ | ចំណុចប្រសព្វទន្លេវ៉ាមកូ-ចំណុចប្រសព្វញ៉ាបែ (ទន្លេសាយហ្គន) | ២០ |
| 3c.3 | ទន្លេសាយហ្គន | ចំណុចប្រសព្វញ៉ាបែ (ទន្លេសាយហ្គ) -កំពង់ផែក្រុងហូជីមិញ | ១៣ |
| 3d.1 | មាត់ពាម | ចំណុចប្រសព្វទន្លេមេគង្គ/ទៀន-ពាមទន្លេសយរ៉ាប់ | ២០ |
| 3d.2 | ទន្លេសយរ៉ាប់ | ពាមទន្លេសយរ៉ាប់-ចំណុចប្រសព្វគេញណុកម៉ាន | ១៦ |
| 3c.2 | ទន្លេសយរ៉ាប់ | ចំណុចប្រសព្វគេញណុកម៉ាន-ចំណុចប្រសព្វសាយហ្គន | ២០ |
| 3c.3 | ទន្លេសាយហ្គន | ចំណុចប្រសព្វសយរ៉ាប់-កំពង់ផែទីក្រុងហូជីមិញ | ១៣ |
| 3d.1 | មាត់ពាម | មាត់ពាមទន្លេមេគង្គ/ទៀន-មាត់ពាមទន្លេសយរ៉ាប់- | ២០ |
| 3e.1 | មាត់ពាម | មាត់ពាមទន្លេសយរ៉ាប់-មាត់ពាមទន្លេសាយហ្គន | ២៥ |
| 3e.2 | ទន្លេសាយហ្គន | មាត់ពាមទន្លេសាយហ្គន-ចំណុចប្រសព្វទន្លេសយរ៉ាប់ | ៣៥ |
| 4 | ទន្លេសាយហ្គន | ព្រំដែនខេត្ត-កំពង់ផែក្រុងហូជីមិញ | ៤៧ |
| 5 | ទន្លេបាសាក់ | ចំណុចប្រសព្វបាសាក់-វ៉ាមណាវ ទៅចំណុចប្រសព្វបាសាក់-បាតេ | ១៦.៤ |
| 6a | ជីតុង-ហ្វវយ៉ាង | ចំណុចប្រសព្វបាសាក់-ជីតុង ទៅ ចំណុចប្រសព្វរ៉ាយ៉ា-ហាទៀង | ៥៨ |
| 6b | រ៉ាយ៉ា-ហាទៀង | រ៉ាយ៉ា-ហាទៀង ទៅរោងចក្រស៊ីម៉ង់ហាទៀង | ៥៦.៩ |

## ៣. ផ្លូវឆ្លងកាត់

ផ្លូវទន្លេមេគង្គ/ទៀន កាត់តាមជ្រោយទៀវហូតដល់កំពង់ផែភ្នំពេញ បន្តកាត់តាមផ្លូវទឹកនិយតកម្មលេខ 1e, 1d, 1c និង 1a នៅប្រទេសវៀតណាម និងផ្លូវទឹកនិយតកម្មលេខ 1c និង 1b នៅប្រទេសកម្ពុជា និង ផ្ទុយមកវិញ។

ផ្លូវទន្លេបាសាក់/ហូវ កាត់តាមជ្រោយឱញអាន បន្តកាត់តាមវាំមណាវជាស និងទន្លេមេគង្គ/ទៀន រហូតដល់កំពង់ផែភ្នំពេញ បន្តកាត់តាមផ្លូវទឹកនិយតកម្មលេខ 2a.3, 2a.2, 2a.1, 1c, 1b និង 1a នៅប្រទេសវៀតណាម និងផ្លូវទឹកនិយតកម្មលេខ 1c និង 1b នៅប្រទេសកម្ពុជា និង ផ្ទុយមកវិញ។

# ឧបសម្ព័ន្ធ B

## ផែនទីផ្លូវទឹក



# ឧបសម្ព័ន្ធ C
## កំពង់ផែ ចំណត និងក្រុមកំពង់ផែ

### ១. បញ្ជីឈ្មោះកំពង់ផែ ចំណត និង ក្រុមកំពង់ផែនៅប្រទេសកម្ពុជា

| ល.រ | ឈ្មោះកំពង់ផែ ចំណត ក្រុមកំពង់ផែ | កម្មសិទ្ធករ | ទន្លេ | ប្រភេទទំនិញ | ចំណាត់ថ្នាក់ទន្លេ | លក្ខណៈបច្ចេកទេស | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | | | បណ្ដោយ (ម) | ទទឹង (ម) | ជំរៅ (ម) | |
| ១ | ផែអណ្ដែត (TS1) | កំពង់ផែស្វយ័តភ្នំពេញ | ទន្លេសាប | ទំនិញរាយ អ្នកដំណើរ | មិនទាន់បានធ្វើចំណាត់ថ្នាក់ | ៤៥ | ១៥ | ៥.៣ | |
| ២ | ចំណតផែកុងតេន័រ (TS3) | កំពង់ផែស្វយ័តភ្នំពេញ | ទន្លេសាប | ទំនិញរាយ កុងតេន័រ | មិនទាន់បានធ្វើចំណាត់ថ្នាក់ | ៣០០ | ២០ | ៦.៣ | |
| ៣ | ចំណតផែក្នុងស្រុក (TS5) | កំពង់ផែស្វយ័តភ្នំពេញ | ទន្លេសាប | ទំនិញរាង | មិនទាន់បានធ្វើចំណាត់ថ្នាក់ | - | - | ៤.៥ | |
| ៤ | ផែអណ្ដែតសូគីមិច (TS7) | ក្រុមហ៊ុនសូគីមិច | ទន្លេសាប | ប្រេង | មិនទាន់បានធ្វើចំណាត់ថ្នាក់ | ៣០ | ៧ | ៤.៦ | |
| ៥ | ផែអណ្ដែតសូគីមិច (TS9) | ក្រុមហ៊ុនសូគីមិច | ទន្លេសាប | ប្រេង | មិនទាន់បានធ្វើចំណាត់ថ្នាក់ | ១៥ | ៥ | ៤ | |
| ៦ | ចំណតគីឡូម៉ែត្រលេខ៦ (TS11) | ក្រុមហ៊ុនគ្រីនត្រេត | ទន្លេសាប | ទំនិញរាយ | មិនទាន់បានធ្វើចំណាត់ថ្នាក់ | ៤០ | ៦ | ៤ | |
| ៧ | ផែព្រែកភ្នៅ (TS15) | ក្រុមហ៊ុនសៀមហ្គាស | ទន្លេសាប | ឧស្ម័ន | មិនទាន់បានធ្វើ | ២បង្គោលចំណត | - | ៥ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | ចំណាត់ថ្នាក់ | | | | |
| ៨ | ចំណតផែតេលា (TS17) | ក្រុមហ៊ុនតេលា | ទន្លេសាប | ប្រេង | មិនទាន់បានធ្វើចំណាត់ថ្នាក់ | ៣០ | ៨ | ៤.៦ | |
| ៩ | ផែប្រាយវិចធីរី (TS19) | ក្រុមហ៊ុនប្រាយ វិកធីរី | ទន្លេសាប | ប្រេង | មិនទាន់បានធ្វើចំណាត់ថ្នាក់ | ២៥ | ៦ | ៤.៦ | |
| ១០ | ចំណតផែម៉ែនសារុន (TS21) | ក្រុមហ៊ុនម៉ែនសារុន | ទន្លេសាប | ទំនិញរាយ | មិនទាន់បានធ្វើចំណាត់ថ្នាក់ | ២០០ | ១៥ | ៥ | |
| ១១ | កំពង់ផែកំពង់ឆ្នាំង | ក្រសួងសាធារណការនិងដឹកជញ្ជូន | ទន្លេសាប | ទំនិញរាយក្នុងស្រុក | មិនទាន់បានធ្វើចំណាត់ថ្នាក់ | ២០ | ៦ | ៤ | |
| ១២ | កំពង់ផែសៀមរាប | ក្រុមហ៊ុនវិនិយោគកំពង់ផែស៊ូជិញ | ទន្លេសាប | ទំនិញរាយ និងអ្នកដំណើរក្នុងស្រុក | មិនទាន់បានធ្វើចំណាត់ថ្នាក់ | - | - | - | កំពុងអភិវឌ្ឍ |
| ១៣ | ចំណតច្រាំងមេគង្គ (សាខាប្រាយវិកធីរី) | ក្រុមហ៊ុនប្រេងមេគង្គប្រាយវិកធីរី | ទន្លេមេគង្គលើ | ប្រេង | មិនទាន់បានធ្វើចំណាត់ថ្នាក់ | - | - | ៥.៥ | |
| ១៤ | ចំណតច្រាំងព្រែកអញ្ចាញ (UM1) | កំពង់ផែស្វយ័តភ្នំពេញ | ទន្លេមេគង្គលើ | ផលិតផលឈើ | មិនទាន់បានធ្វើចំណាត់ថ្នាក់ | - | - | ៥ | |
| ១៥ | ចំណតច្រាំងទន្លេបិទ (UM2) | កំពង់ផែស្វយ័តភ្នំពេញ | ទន្លេមេគង្គលើ | ទំនិញរាយ | មិនទាន់បានធ្វើចំណាត់ថ្នាក់ | - | - | ៥ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១៦ | ចំណតផែក្នុងស្រុកកំពង់ចាម (UM3) | កំពង់ផែស្វយ័តភ្នំពេញ | ទន្លេមេគង្គលើ | ទំនិញរាយ និង អ្នកដំណើរ | មិនទាន់បានធ្វើចំណាត់ថ្នាក់ | - | - | ៤ | |
| ១៧ | ផែជីឥដ្ឋ (LM5) | កំពង់ផែស្វយ័តភ្នំពេញ | ទន្លេមេគង្គក្រោម | ទំនិញរាយ | មិនទាន់បានធ្វើចំណាត់ថ្នាក់ | ៣៥ | ២០ | ១៤ | |
| ១៨ | ផែអណ្តែតតូតាល់ (LM11) | ក្រុមហ៊ុនតូតាល់ | ទន្លេមេគង្គក្រោម | ប្រេង ឧស្ម័ន | មិនទាន់បានធ្វើចំណាត់ថ្នាក់ | ៣០ | ៦ | ១០ | |
| ១៩ | ចំណតផែកុងតេន័រថ្មី (LM17) | កំពង់ផែស្វយ័តភ្នំពេញ | ទន្លេមេគង្គក្រោម | - | មិនទាន់បានធ្វើចំណាត់ថ្នាក់ | - | - | ១០ | កំពុងអភិវឌ្ឍ |
| ២០ | ផែអណ្តែតប៉េត្រូណាស់ (LM19) | ក្រុមហ៊ុនប៉េត្រូណាស់ | ទន្លេមេគង្គក្រោម | ប្រេង | មិនទាន់បានធ្វើចំណាត់ថ្នាក់ | ៣០ | ៦ | ១៤ | |
| ២១ | ផែអណ្តែតព្រែកខ្សាយ | ក្រុមហ៊ុនវិនិយោគ អាស៊ាន LHR | ទន្លេមេគង្គក្រោម | ប្រេង | មិនទាន់បានធ្វើចំណាត់ថ្នាក់ | ២០ | ៦ | ២ | |
| ២២ | ផែសូគីមិចព្រែកខ្សាយ (LM2) | ក្រុមហ៊ុនសូគិមិច | ទន្លេមេគង្គក្រោម | ប្រេង | មិនទាន់បានធ្វើចំណាត់ថ្នាក់ | - | - | ៣ | |
| ២៣ | អ្នកលឿង | កំពង់ផែស្វយ័តភ្នំពេញ | ទន្លេមេគង្គក្រោម | ទំនិញរាយ | មិនទាន់បានធ្វើចំណាត់ថ្នាក់ | - | - | ៤ | |
| ២៤ | ចំណតសាជីវកម្មម្សៅមីអាស៊ី (TB3) | ក្រុមហ៊ុនម្សៅមីអាស៊ី | ទន្លេបាសាក់ | ទំនិញរាយ | មិនទាន់បានធ្វើចំណាត់ថ្នាក់ | - | - | ៦ | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៥ | ផែអណ្តែតចាក់អង្រែ (TB5) | ក្រុមហ៊ុនអ៊ីឌីស៊ីចាក់អង្រែ | ទន្លេបាសាក់ | ប្រេង | មិនទាន់បានធ្វើចំណាត់ថ្នាក់ | ២៥ | ៦ | ៤ | |

**បញ្ជីឈ្មោះកំពង់ផែ ចំណត និង ក្រុមកំពង់ផែនៅប្រទេសវៀតណាម**

| ល.រ | ឈ្មោះកំពង់ផែ ចំណត ក្រុមកំពង់ផែ | កម្មសិទ្ធករ | ទន្លេ | ប្រភេទទំនិញ | ចំណាត់ថ្នាក់ទន្លេ | លក្ខណៈបច្ចេកទេស | | |
|---|---|---|---|---|---|---|---|---|
| | | | | | | បណ្តោយ (ម) | ទទឹង (ម) | ជំរៅ (ម) |
| ១ | កំពង់ផែរោងចក្រថាមពលធូឌឹក | រោងចក្រថាមពលធូឌឹក | គេញសាង | ប្រេង | ថ្នាក់ទី៣ | ១២០ | ១៥ | ៣.០ |
| ២ | កំពង់ផែភស្តុភារមៀនណាម | ក្រុមហ៊ុនភស្តុភារមៀនណាម | គេញសាង | កុងតេន័រ ទំនិញរាយ | ថ្នាក់ទី៣ | ១២០ | ១៥ | ៣.០ |
| ៣ | កំពង់ផែរោងចក្រដែកថែបមៀនណាម | ក្រុមហ៊ុនដែកថែបមៀនណាម | គេញសាង | រ៉ែដែក | ថ្នាក់ទី៣ | ៤៥ | ១៥ | ៣.០ |
| ៤ | កំពង់ផែតីណាម | ក្រុមហ៊ុនពាណិជ្ជកម្មតីណាម | សាយហ្គន | កុងតេន័រ ទំនិញរាយ | ថ្នាក់ទី២ | ១៣០ | ២៥ | ៤.៥ |
| ៥ | កំពង់ផែជឿងឌី | ក្រុមហ៊ុនមេកានិក | សាយហ្គន | កុងតេន័រ ទំនិញរាយ | ថ្នាក់ទី៣ | ៤៦០ | ៣០ | ៤.៥ |
| ៦ | កំពង់ផែត្រង់ស៊ីមិច | ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | សាយហ្គន | កុងតេន័រ ទំនិញរាយ | ថ្នាក់ទី៣ | ១០០ | ៣០ | ៤.៥ |
| ៧ | កំពង់ផែភឿកឡុង | ក្រុមហ៊ុនស្តុករួមភឿកឡុង | សាយហ្គន | កុងតេន័រ ទំនិញរាយ | ថ្នាក់ទី៣ | ៨០ | ៣០ | ៤.៥ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៨ | កំពង់ផែហ្វាងឡុង | ក្រុមហ៊ុនហ្វាងឡុង | ដុងណាយ | ទំនិញរាយ | ថ្នាក់ទី៤ | ៥០ | ១៥ | ៣.០ |
| ៩ | កំពង់ផែហ្វាងទន់ | ក្រុមហ៊ុនហ្វាងទន់ | វ៉ាមកូដុង | កុងតេន័រ ទំនិញរាយ | ថ្នាក់ទី៣ | ៥០ | ១៥ | ៣.០ |
| ១០ | កំពង់ផែទន់ថាត់ឡៀត | ក្រុមហ៊ុនសាជីវកម្ម ដឹកជញ្ជូនផ្លូវទឹក ភាគខាងត្បូង | គេញ្ជូតេ | ទំនិញរាយ | ថ្នាក់ទី៣ | ២២០ | ១៥ | ៣.០ |
| ១១ | កំពង់ផែតីនិញ | ក្រុមហ៊ុនប្រេង និង ឧស្ម័នតីនិញ | វ៉ាមកូដុង | ប្រេង និងឧស្ម័ន | ថ្នាក់ទី៤ | ៦០ | ៣០ | ៣.០ |
| ១២ | រោងចក្រស៊ីម៉ង់សាយហ្គន | រោងចក្រស៊ីម៉ង់ សាយហ្គន | ដុងណៃ | ស៊ីម៉ង់ | ថ្នាក់ទី៣ | ៨០ | ៣០ | ៣.០ |
| ១៣ | កំពង់ផែប្រេងឡុងប៊ិញតាន | ក្រុមហ៊ុនប្រេងដុងណៃ | ដុងណៃ | ប្រេង | ថ្នាក់ទី៤ | ១២០ | ៣០ | ៣.០ |
| ១៤ | កំពង់ផែទីនងៀ | ក្រុមហ៊ុនទីនងៀ | ដុងណៃ | ទំនិញរាយ | ថ្នាក់ទី៣ | ១២៤ | ៣០ | ៤.០ |
| ១៥ | កំពង់ផែថាញ់តៃ | ក្រុមហ៊ុនពាណិជ្ជកម្ម ថាញ់តៃ | វ៉ាមកូដុង | ទំនិញរាយ ប្រេង | ថ្នាក់ទី៣ | ៣០០ | ២០ | ៤.៥ |
| ១៦ | កំពង់ផែបឿកបុង | ក្រុមហ៊ុនបេនលុកបឿកបុង | វ៉ាមកូដុង | ឧស្ម័ន | ថ្នាក់ទី៣ | ២០០ | ២០ | ៤.៥ |
| ១៧ | កំពង់ផែឧស្ម័នអ៊ិមធី | ក្រុមហ៊ុនឧស្ម័នអ៊ិមធី | វ៉ាមកូដុង | ទំនិញរាយ ឧស្ម័ន | ថ្នាក់ទី៣ | ១៤០ | ១៦ | ៤.៥ |
| ១៨ | កំពង់ផែឡុងប៊ិញ | ក្រុមហ៊ុនសាជីវកម្ម ដឹកជញ្ជូនផ្លូវទឹកភាគ ខាងត្បូង | ដុងណៃ | ទំនិញរាយ | ថ្នាក់ទី២ | ៥៦០ | ៣០ | ៤.៥ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៩ | រោងចក្រស៊ីម៉ងហាទៀងទី២ | ក្រុមហ៊ុនស៊ីម៉ងហាទៀង-កាន់ធី | បាសាក់ | ទំនិញរាយ | ថ្នាក់ទី៣ | ៥០ | ១៥ | ៤.០ |
| ២០ | កំពង់ផែវិញឡឹម | សហគ្រាសវិញឡឹម | បាសាក់ | ទំនិញរាយ | ថ្នាក់ទី៤ | ៥០ | ១៥ | ៤.០ |
| ២១ | កំពង់ផែបរិក្ខាអានយ៉ាង | ក្រុមហ៊ុនបរិក្ខាអានយ៉ាង | វ៉ាច់កាន់ធី | ទំនិញរាយ | ថ្នាក់ទី៤ | - | - | ២.៦ |
| ២២ | កំពង់ផែប្រេងកៃរ៉ាំង | ក្រុមហ៊ុនប្រេងណាមបូ | វ៉ាច់កាន់ធី | ទំនិញរាយ | ថ្នាក់ទី៤ | - | - | ២.៨ |
| ២៣ | កំពង់ផែឌឹកឡូង | ហេដ្ឋារចនាសម្ព័ន្ធឌឹកឡូង | កូជីម | ទំនិញរាយ | ថ្នាក់ទី៣ | - | - | ២.៥ |
| ២៤ | រោងចក្រស៊ីម៉ងហាទៀង-គៀនយ៉ាង | ក្រុមហ៊ុនស៊ីម៉ងហាទៀងទី២ | គេញបាហូន | ទំនិញរាយ | ថ្នាក់ទី៣ | - | - | ២.៤ |
| ២៥ | កំពង់ផែឡុងប៊ិញ | ក្រុមកំពង់ផែមីថយ-អានយ៉ាង | បាសាក់ | ទំនិញរាយ | ថ្នាក់ទី៣ | - | - | ២.៥ |
| ២៦ | កំពង់ផែបាវម៉ៃ | សហគ្រាសបាវម៉ៃ | បាសាក់ | ទំនិញរាយ | ថ្នាក់ទី៤ | - | - | ២.៥ |
| ២៧ | កំពង់ផែអ្នកដំណើរចូវដុក | ផ្នែកគ្រប់គ្រងអ្នកទេសចរអានយ៉ាង | បាសាក់ | អ្នកដំណើរ | ថ្នាក់ទី២ | - | - | ២.០ |
| ២៨ | កំពង់ផែវៀតយិន | ក្រុមហ៊ុននាំចេញនាំចូលត្រីដុងថាប់ | កូជីម | ទំនិញរាយ | ថ្នាក់ទី៤ | - | - | ២.៥ |
| ២៩ | ក្រុមកំពង់ផែសមុទ្រសាយ ហ្គូន | - | សាយហ្គូន | - | ផ្លូវសមុទ្រ | - | - | - |
| ៣០ | ក្រុមកំពង់ផែសមុទ្រញ៉ាបែ | - | ញ៉ាបែ ឡុងតាវ | - | ផ្លូវសមុទ្រ | - | - | - |
| ៣១ | ក្រុមកំពង់ផែសមុទ្រកៃឡាត | - | ដុងណៃ | - | ផ្លូវសមុទ្រ | - | - | - |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣២ | ក្រុមកំពង់ផែសមុទ្រហៀបភឿក | - | សយវ៉ាប់ | - | ផ្លូវសមុទ្រ | - | - | - |
| ៣៣ | តំបន់ផ្ទេរទំនិញ | - | ផៀនលៀង | - | ផ្លូវសមុទ្រ | - | - | - |
| ៣៤ | តំបន់ឧស្សាហកម្មដុងណៃ | - | ដុងណៃ | - | ផ្លូវសមុទ្រ | - | - | - |
| ៣៥ | តំបន់កំពង់ផែហ្គោយ៉ូវ ភឿក អាន ភូមី កៃមេប | - | ធីវ៉ាយ | - | ផ្លូវសមុទ្រ | - | - | - |
| ៣៦ | ក្រុមកំពង់ផែសមុទ្រវ៉ង់តាវ | - | ឌិញ | - | ផ្លូវសមុទ្រ | - | - | - |
| ៣៧ | ក្រុមកំពង់ផែសមុទ្រកាន់ថឺ | - | បាសាក់ | - | ផ្លូវសមុទ្រ | - | - | - |
| ៣៨ | ក្រុមកំពង់ផែសមុទ្រដុងថាប់ | - | មេគង្គ | - | ផ្លូវសមុទ្រ | - | - | - |
| ៣៩ | ក្រុមកំពង់ផែសមុទ្រមីថ | - | មេគង្គ | - | ផ្លូវសមុទ្រ | - | - | - |
| ៤០ | តំបន់កំពង់ផែហួនជឿង រ៉ាច់យ៉ា | - | - | - | ផ្លូវសមុទ្រ | - | - | - |

## ឧបសម្ព័ន្ធ D

## ទម្រង់លិខិតអនុញ្ញាតដឹកជញ្ជូនឆ្លងកាត់ព្រំដែន

គំរូ

**ព្រះរាជាណាចក្រកម្ពុជា**

**ឬ**

**សាធារណរដ្ឋសង្គមនិយមវៀតណាម**

(ដាក់បញ្ចូលប៉ាវចនាជាតិ និង/ឬ សញ្ញានៃអាជ្ញាធរចេញលិខិតអនុញ្ញាត)

**លិខិតអនុញ្ញាតដឹកជញ្ជូនឆ្លងកាត់ព្រំដែន**

ទំព័រទី១

**ព្រះរាជាណាចក្រកម្ពុជា**

**ឬ**

**សាធារណរដ្ឋសង្គមនិយមវៀតណាម**

(ដាក់បញ្ចូលប៉ាវចនាជាតិ និង/ឬ សញ្ញានៃអាជ្ញាធរចេញលិខិតអនុញ្ញាត)

**លិខិតអនុញ្ញាតដឹកជញ្ជូនឆ្លងកាត់ព្រំដែន**

ចេញឱ្យស្របតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក

(ដាក់បញ្ចូលឈ្មោះអាជ្ញាធរចេញលិខិតអនុញ្ញាត)

☐ សម្រាប់នាវាផ្លូវទឹកក្នុងប្រទេស ដែលធ្វើការដឹកជញ្ជូនច្រើនលើក (ថ្នាក់ទី១)

☐ សម្រាប់នាវាផ្លូវទឹកក្នុងប្រទេស ដែលធ្វើការដឹកជញ្ជូនមួយលើក (ថ្នាក់ទី២)

☐ សម្រាប់នាវាផ្លូវទឹកក្នុងប្រទេស ដែលដឹកទំនិញគ្រោះថ្នាក់ (ថ្នាក់ទី៣)

(ជ្រើសយកប្រអប់ណាមួយ)

ទំព័រទី២

ការចេញ និង សុពលភាព

លិខិតអនុញ្ញាតដឹកជញ្ជូនឆ្លងកាត់ព្រំដែនលេខ No. ........................................

ប្រទេសចេញ: ........................................

អាជ្ញាធរចេញៈ .......................................

ទីកន្លែងចេញៈ .......................................

កាលបរិច្ឆេទចេញៈ .......................................

កាលបរិច្ឆេទផុតកំណត់ៈ .......................................

ថ្នាក់ៈ (ឬមួយ នាវាផ្លូវទឹកដែលធ្វើការដឹកជញ្ជូនច្រើនលើក - ថ្នាក់ទី១ ឬមួយ នាវាផ្លូវទឹកដែលធ្វើការដឹកជញ្ជូនមួយលើក - ថ្នាក់ទី២ ឬ មួយ នាវាផ្លូវទឹកដែលដឹកទំនិញគ្រោះថ្នាក់ - ថ្នាក់ទី៣)

ដាក់ឈ្មោះនាវា : .........................................................................................

(ដាក់បញ្ចូលឈ្មោះ និង/ឬត្រា និង/ឬហត្ថលេខារបស់មន្ត្រីអាជ្ញាធរចេញលិខិតអនុញ្ញាត)

ទំព័រទី៣

ការចេញឡើងវិញ

កាលបរិច្ឆេទចេញៈ.............................................

កាលបរិច្ឆេទផុតកំណត់ៈ....................................

ទីកន្លែងចេញៈ..................................................

មូលវិចារសម្គាល់ៈ..................................................

(ដាក់ឈ្មោះ និង/ឬ ត្រា និង/ឬហត្ថលេខាមន្ត្រីអាជ្ញាធរចេញលិខិតអនុញ្ញាត)

ទំព័រទី៤

ភិនភាគនាវា

ឈ្មោះនាវាៈ...............................................................

ប្រភេទ និងគោលបំណងរបស់នាវាៈ...................................

លេខចុះបញ្ជីៈ...........................................................

ចំណុះសរុបៈ..............................................................

ទំងន់ផ្ទុកសរុបៈ...........................................................

បណ្ដោយៈ.................................................................

ទទឹងៈ.......................................................................

ជំរៅស៊ីទឹកអតិបរមាៈ.....................................................

ឆ្នាំផលិតៈ.................................................................

ប្រភេទ និងចំនួនម៉ាស៊ីនៈ...................................................

ល្បឿនអតិបរមាៈ...........................................................

កំលាំងសេះ/គីឡូវ៉ាត់ៈ......................................................

ទំព័រទី៥

ភិនភាគម្ចាស់ ឬ ប្រតិបត្តិករ

ម្ចាស់នាវា ឬ ប្រតិបត្តិករនាវាៈ........................................................

អាស័យដ្ឋានរបស់ម្ចាស់នាវា ឬ ប្រតិបត្តិករនាវាៈ.................................

(បើសិនជាមាននៅក្នុងច្បាប់ជាតិ)ៈ លេខលិខិតអនុញ្ញាតរបស់ក្រុមហ៊ុន ឬ របស់ប្រតិបត្តិករៈ............................

ទីកន្លែងចេញៈ......................................

កាលបរិច្ឆេទចេញៈ................................

កាលបរិច្ឆេទផុតកំណត់ៈ.........................

ទំព័រទី៦

ផ្លូវ កំពង់ផែ ចំណត និងក្រុមកំពង់ផែ

នៅក្នុងកថាខ័ណ្ឌទី៤ មាត្រា១៥ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក (ប្រសិនបើចាំបាច់)

ផ្លូវបញ្ញត្តិកម្មៈ..........................................

កំពង់ផែ ចំណត និង/ឬក្រុមកំពង់ផែបញ្ញត្តិកម្មៈ..............................................

ទំព័រទី៧-៤៧

វិញ្ញាបនប័ត្រ

ការពិនិត្យសង្ខេប នៅតាមច្រកទ្វារព្រំដែន និង ការត្រួតពិនិត្យ នៅតាមកំពង់ផែ ឬ ចំណតចេញដំណើរ និង នៅតាមកំពង់ផែ ឬ ចំណតគោលដៅៈ.......................................................

ទំព័រទី៤៨

វិធានប្រើប្រាស់

១. លិខិតអនុញ្ញាតនេះ មាន៤៨ទំព័រ ដោយមិនគិតពីគំរបក្រប ។

២. លិខិតអនុញ្ញាតនេះ ត្រូវដាក់នៅតាមនាវា និង ត្រូវបង្ហាញដល់អាជ្ញាធរមានសមត្ថកិច្ច នៅពេលមានការស្នើសុំ ។

៣. លិខិតអនុញ្ញាតនេះ ត្រូវប្រើប្រាស់សម្រាប់តែនាវា ដែលមានឈ្មោះនៅក្នុងលិខិតនេះប៉ុណ្ណោះ ។

៤. លិខិតអនុញ្ញាតនេះ មិនត្រូវបានពន្យាពេលលើសពីម្តងឡើយ និង ត្រូវមានសុពលភាពរហូតដល់កាលបរិច្ឆេទផុតកំណត់ ។

៥. លិខិតអនុញ្ញាតនេះ ដែលបានផុតកំណត់ហើយ ត្រូវប្រគល់ជូនអាជ្ញាធរចេញលិខិតអនុញ្ញាតវិញ ។

៦. រាល់ការកែប្រែ ការសរសេរបន្ថែម ឬ ការធ្វើវិសោធនកម្មណាមួយលើលិខិតអនុញ្ញាតនេះ ត្រូវហាមឃាត់ដាច់ខាត ។ នៅក្នុងករណីបាត់បង់ ត្រូវរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរចេញលិខិតអនុញ្ញាតនេះ ។

៧. នាវា ត្រូវធ្វើដំណើរតែនៅតាមផ្លូវដែលបានបញ្ជាក់ និងទៅមកកំពង់ផែ ចំណត និង ក្រុមកំពង់ផែដែលបានបញ្ជាក់ ប៉ុណ្ណោះ ។ ប្រសិនបើពុំមានផ្លូវ កំពង់ផែ ចំណត ឬ ក្រុមកំពង់ផែ ត្រូវបានកំណត់ជាក់លាក់នៅក្នុងលិខិត អនុញ្ញាតនេះទេ នោះនាវា ដែលធ្វើការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ផ្លូវទឹកនិយតកម្ម និងកំពង់ផែ ចំណត និងក្រុមកំពង់ផែណាមួយក៏បាន ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល កម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក ។